លេខ: D349/6

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des Tribunaux cambodgiens

ការិយាល័យសហចៅក្រមស៊ើបអង្កេត
Office of the Co-Investigating Judges
Bureau des co-juges d'instruction

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 11-Aug-2017, 13:26
CMS/CFO: Sann Rada

**សំណុំរឿងលេខ៖ ០០៤/២/០៧-០៩-២០០៩-អ.វ.ត.ក-ក.ស.ច.ស**

ចំពោះមុខ ៖ **សហចៅក្រមស៊ើបអង្កេត**

កាលបរិច្ឆេទ ៖ **ថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០១៧**

ភាសា ៖ **អង់គ្លេស និង ខ្មែរ**

ចំណាត់ថ្នាក់ឯកសារ ៖ **សាធារណៈ: កោសលុប**

---

# ដីកាសម្រេចរួមលើផលប៉ះពាល់ដោយសារស្ថានភាពថវិកាមកលើសំណុំរឿង ០០៣ សំណុំរឿង ០០៤ និងសំណុំរឿង ០០៤/២ និងសារណាពាក់ព័ន្ធនានារបស់មេធាវីការពារក្តី យឹម ទិត្យ

---

**ផ្ញើជូន ៖**

**សហព្រះរាជអាជ្ញា**
ជា លាង
Nicholas KOUMJIAN

**មេធាវីការពារក្តី អោ អាន**
មុំ លុជ្ស
Richard ROGERS
Göran SLUITER

**ការិយាល័យរដ្ឋបាល**
ឯកឧត្តម ក្រាញ់ តូនី
Knut ROSANDHAUG

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី**
ជេត វណ្ណលី
ហុង គឹមសួន
គីម ម៉េងឃី
ឡោ ជុនធី
សំ សុគង់
ស៊ិន ស៊ីវ៉ន
ទី ស្រីនណា
វែន ពៅ

Laure DESFORGES
Isabelle DURAND
Emmanuel JACOMY
Martine JACQUIN
Lyma NGUYEN
Nushin SARKARATI

01522520



## ១. ប្រវត្តិនីតិវិធី

១. នៅថ្ងៃទី ៥ ខែ មិថុនា ឆ្នាំ ២០១៧ យើងបានទទួលមតិយោបល់នានា យោងលើសំណើសុំមតិយោបល់របស់យើងចុះថ្ងៃទី ៥ ខែ ឧសភា ឆ្នាំ ២០១៧ ("សំណើ")[1] ពីការិយាល័យរដ្ឋបាល[2] រាប់បញ្ចូលទាំងសេចក្តីបញ្ជាក់ពីអង្គការសហប្រជាតិ ("អ.ស.ប")[3] ក្រុមប្រទេសផ្តល់ជំនួយសំខាន់ៗ[4] និងលោក David Scheffer អ្នកជំនាញពិសេសរបស់អគ្គលេខាធិការ[5] ព្រមទាំងមតិយោបល់ពីមេធាវីការពារក្តី មាស មុត[6] មេធាវីការពារក្តី អោ អាន[7] មេធាវីការពារក្តី យឹម ទិត្យ[8] និងសហព្រះរាជអាជ្ញាអន្តរជាតិ("ស.ព.អ")[9]។ យើងកត់សម្គាល់ថា រាជរដ្ឋាភិបាលកម្ពុជា ទោះបីថាជាភាគីមួយនៅក្នុងចំណោមភាគី កិច្ចព្រមព្រៀងរវាង អ.ស.ប ជាមួយរាជរដ្ឋាភិបាលកម្ពុជាក្នុងការបង្កើត អ.វ.ត.ក ក៏ដោយ ក៏មិនបានដាក់ចម្លើយដាច់ដោយ

---

1 [redacted]

2 [redacted]

3 [redacted]

4 [redacted]

5 [redacted]

6 [redacted]

7 [redacted]

8 [redacted]

9 [redacted] *អ.វ.ត.ក និងផលប៉ះពាល់របស់វាលើសំណុំរឿង ០០៣, ០០៤ និង ០០៤/២* ថ្ងៃទី ៥ ខែ មិថុនា ឆ្នាំ ២០១៧។

ឡែកផ្ញើជូនការិយាល័យរដ្ឋបាលដែរ។ សហព្រះរាជអាជ្ញាជាតិ និងដើមបណ្តឹងរដ្ឋប្បវេណី ក៏មិនបានដាក់មតិយោបល់ណាមួយដែរ។

២. យើងយោងលើឯកសារទាំងនោះសម្រាប់ព័ត៌មានលម្អិត ហើយដើម្បីចៀសវាងភាពច្រំដែល យើងនឹងធ្វើការដកស្រង់ពីឯកសារទាំងនោះតែក្នុងករណីចាំបាច់។

៣. តាមរយៈអនុស្សរណៈចុះថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១៧[10] យើងបានជូនដំណឹងភាគីទាំងអស់ និងការិយាល័យរដ្ឋបាល ថា កាលបរិច្ឆេទកំណត់ពីដើមដើម្បីចេញដីកាសម្រេចរបស់យើង នៅត្រឹមថ្ងៃទី ៣១ ខែ មិថុនា ឆ្នាំ ២០១៧ បានទុកជាមោឃៈ ពីព្រោះថា យើងទទួលបានការជូនដំណឹងថា កិច្ចសន្យាការងារបុគ្គលិកនឹងត្រូវបន្តហួសពីកាលបរិច្ឆេទនេះ។ ជាពិសេស នៅថ្ងៃទី ២៦ ខែឧសភា ឆ្នាំ២០១៧ អនុប្រធានការិយាល័យរដ្ឋបាល បានជូនដំណឹងបុគ្គលិក ថា កិច្ចសន្យាការងារនឹងបន្តរហូតដល់ខែកញ្ញា ឆ្នាំ២០១៧ ហើយ នៅថ្ងៃទី ២៧ ខែមិថុនា ឆ្នាំ ២០១៧ បុគ្គលិកត្រូវបានជូនដំណឹងថែមទៀតថា កិច្ចសន្យាការងារនឹងត្រូវបន្តរហូតដល់ចុងឆ្នាំ ២០១៧ [11]។ ដោយពិនិត្យឃើញថា ការផ្អាកកិច្ចដំណើរការនីតិវិធីមានផលប៉ះពាល់ធំធេង ហើយមិនចាំបាច់បន្តឱ្យមានដីកាសម្រេចជាបន្ទាន់នោះទេ ទើបយើងផ្អៀតពេលនៃការពន្យារពេលនេះ ដើម្បីពិចារណាលើមតិយោបល់នានាឱ្យបានស៊ីជម្រៅ ខណៈដែលពេលដំណាលគ្នានេះ យើងនៅតែបន្តកិច្ចដំណើរការនីតិវិធីសំណុំរឿងឱ្យមានប្រសិទ្ធភាពតាមដែលអាចធ្វើទៅបាន។

៤. ក្នុងរយៈពេលប៉ុន្មានម៉ោងបន្ទាប់ពីសំណើបានដាក់ចេញ សំណើ ឬក៏យ៉ាងហោចណាស់ ការដកស្រង់នៃសំណើបានបែកធ្លាយដល់សារព័ត៌មានភ្នំពេញប៉ុស្តិ៍ ទាំងមិនស្របច្បាប់ ដោយ

---

[10] [redacted]

[11] ព័ត៌មាននេះត្រូវបានផ្សព្វផ្សាយជាលើកដំបូងតាមរយៈអ៊ីមែលពីលោក Knut Rosandhaug អនុប្រធានការិយាល័យរដ្ឋបាល នៅថ្ងៃទី ២៦ ខែ ឧសភា និងថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០១៧។ នៅថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១៧ ការិយាល័យរដ្ឋបាល បានផ្ញើអនុស្សរណៈអន្តរការិយាល័យជាផ្លូវការជូនសហចៅក្រមស៊ើបអង្កេត ដោយជូនដំណឹងសហចៅក្រមថា កិច្ចសន្យាការងាររបស់បុគ្គលិកអន្តរជាតិ ត្រូវបានបន្តរហូតដល់ចុងឆ្នាំ ២០១៧ ហើយកិច្ចសន្យាការងាររបស់បុគ្គលិកជាតិ កំពុងស្ថិតនៅក្នុងដំណើរការត្រូវបន្ត *សូមមើល* ឯកសារ D349/5 *អនុស្សរណៈអន្តរការិយាល័យពីការិយាល័យរដ្ឋបាល កម្មវត្ថុ ព័ត៌មានបន្ថែមទាក់ទងនឹង "សំណើសុំមតិយោបល់អំពីស្ថានភាពថវិការបស់ អ.វ.ត.ក និងផលប៉ះពាល់មកលើសំណុំរឿង ០០៣ សំណុំរឿង ០០៤ និងសំណុំរឿង ០០៤/២"* ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១៧។

រំលោភលើភារកិច្ចត្រូវរក្សាការសម្ងាត់។ បញ្ហានេះនាំឱ្យមានការផ្សព្វផ្សាយនៅក្នុងប្រព័ន្ធផ្សព្វផ្សាយយ៉ាងក្តៅគគុក ហើយក៏នាំឱ្យមានមតិយោបល់ពីមនុស្សមួយចំនួនទាំងនៅក្នុង អ.វ.ត.ក ទាំងនៅក្រៅ អ.វ.ត.ក ដោយធ្វើការស្នើសុំផ្សេងៗ ដូចជា ការស្នើសុំឱ្យដាក់សំណើជាសាធារណៈ ដើម្បីអាចមានការពិភាក្សាជាសាធារណៈអំពីអង្គសេចក្តីនៃសំណើ ដោយហេតុថាការដាក់សំណើជាឯកសារសម្ងាត់ គឺស្មើនឹង"ការបដិសេធដំណើរការនីតិវិធីត្រឹមត្រូវ" ពីព្រោះថានេះគឺជា"បញ្ហារដ្ឋបាលសុទ្ធសាធ"[12]។

## ២. សារណា

៥. ចម្លើយតបរបស់ភាគីទៅនឹងសំណើរបស់យើង បានធ្វើឡើងតាមខ្លឹមសារដូចខាងក្រោម៖ ក្រុមមេធាវីការពារក្តីទាំងអស់ សុទ្ធតែគាំទ្រឱ្យផ្អាកកិច្ចដំណើរការនីតិវិធីជាអចិន្ត្រៃយ៍ឱ្យបានឆាប់បំផុត[13] ចំណែកឯ ស.ព.អ ទោះជាបានចែករំលែក"ការអាក់អន់ស្រពន់ចិត្ត"[14]របស់យើងអំពី

---

[12] សូមមើល Andrew Nachemson &Erin Handley *ការផ្អាកសំណុំរឿងនៅសាលាក្តីខ្មែរក្រហមត្រូវបានពិចារណា* ភ្នំពេញប៉ុស្តិ៍ ថ្ងៃទី ៨ ខែ ឧសភា ឆ្នាំ ២០១៧ គេហទំព័រ៖ http://www.phnompenhpost.com/national/staying-khmer-rouge-tribunal-cases-mulled។ Erin Handley& គង់ មេគ្គា *ចៅក្រមសាលាក្តីខ្មែរក្រហម "បារម្ភយ៉ាងខ្លាំង" អំពីអនាគត* ភ្នំពេញប៉ុស្តិ៍ ថ្ងៃទី ៩ ខែ ឧសភា ឆ្នាំ ២០១៧ គេហទំព័រ៖ http://www.phnompenhpost.com/national/khmer-rouge-tribunal-judges-have-deep-concerns-about-future។ Andrew Nachemson&Erin Handley *ការផ្អាកសំណុំរឿង គឺជា "ការបដិសេធដំណើរការនីតិវិធីត្រឹមត្រូវ"* ភ្នំពេញប៉ុស្តិ៍ ថ្ងៃទី ១០ ខែឧសភា ឆ្នាំ ២០១៧ គេហទំព័រ៖ http://www.phnompenhpost.com/national/stay-denial-due-process ។ Michael G. Karnavas *ដំណើរការនីតិវិធីត្រឹមត្រូវ មិនអាចចរចាបានឡើយ សូម្បីតែនៅសាលាក្តីខ្មែរក្រហមក៏ដោយ* ខេមបូឌា ដេលី ថ្ងៃទី ១៥ ខែឧសភា ឆ្នាំ ២០១៧ គេហទំព័រ៖ https://www.cambodiadaily.com/opinion/opinion-due-process-not-negotiable-even-khmer-rouge-tribunal-129742/។

[13] [redacted]

[14]

01522523



ស្ថានភាពថវិកាក៏ដោយ ក៏នៅតែយល់ឃើញថា ការពិចារណារបស់យើងក្នុងការផ្អាកកិច្ចដំណើរការនីតិវិធីគឺថា "ជាចម្បងមិនសមហេតុផល"ទេ[15] ហើយដីកាសម្រេចផ្អាកកិច្ចដំណើរការនីតិវិធីគឺ "*ហួសដែនអំណាច*" [16]។

៦. ចម្លើយតបរបស់ការិយាល័យរដ្ឋបាល ភាគច្រើនគឺជាការរៀបរាប់អំពីការវិវត្តថវិកា និងការផ្តល់ថវិកា ដោយមួយផ្អែកផ្អែកលើឧបសម្ព័ន្ធ ១ ដល់ ៣។ ចម្លើយតបនេះបង្ហាញពីការកើនឡើងនាពេលថ្មីៗនេះនូវថវិកាស្ម័គ្រចិត្ត ដែលរាប់បញ្ចូលទាំងការសន្យានានា ត្រូវបានលើកឡើងថាបានបំពេញកង្វះថវិកាពីមុន ច្រើនជាង ២ លានដុល្លារ[17]។

៧. ខ្លឹមសារនៃចំណុចផ្សេងៗដែលបានលើកឡើងនៅក្នុងចម្លើយឡាស់លាស់ចុងក្រោយពី អ.ស.ប ក្រុមប្រទេសផ្តល់ជំនួយសំខាន់ៗ និងខ្លឹមសារតិចជាងនេះទេពីអ្នកជំនាញពិសេសរបស់អគ្គលេខាធិការ អាចត្រូវសង្ខេបដូចខាងក្រោម៖

ក. អាណត្តិរបស់សហចៅក្រមស៊ើបអង្កេត ("ស.ច.ស") មិនរាប់បញ្ចូលការសម្រេចលើផ្នែកហិរញ្ញវត្ថុពាក់ព័ន្ធនឹងថវិកា និងការផ្តល់ថវិកាទេ ហើយ ស.ច.ស គួរតែផ្តោតលើការបំពេញកិច្ចស៊ើបសួរ ហើយសម្រេចរឿងក្តីដោយផ្អែកលើអង្គច្បាប់[18]។

---

15 [redacted]

16 [redacted]

17 [redacted]

18 [redacted]

01522524



ខ. យ៉ាងណាក៏ដោយ សេចក្ដីព្រួយបារម្ភផ្នែកហិរញ្ញវត្ថុនៅដំណាក់កាលបន្ទាប់ពីការស៊ើបសួរបានបញ្ចប់នោះ គឺជាបញ្ហាសម្រាប់ចៅក្រមនៃអង្គជំនុំជម្រះដែលទទួលពិនិត្យសំណុំរឿងក្រោយពីចេញដីកាដំណោះស្រាយ[19]។

គ. មិនមានវិបត្តិហិរញ្ញវត្ថុខុសធម្មតា ដូចដែលបានបង្ហាញនៅក្នុងសំណើទេ ហើយមិនច្បាស់ថាតើហេតុអ្វីបានជា ស.ច.ស គួរមានអារម្មណ៍ថាមានវិបត្តិបែបនេះទៅវិញ ជាពិសេស ដោយសារថា ស.ច.ស មិនបានផ្ដល់ព័ត៌មានលម្អិត ឬការវិភាគថែមទៀតទេ[20]។

ឃ. ស្ថានភាពថវិកានៅ អ.វ.ត.ក តែងតែមានការលំបាក ហើយឧទាហរណ៍ពីតុលាការអន្តរជាតិផ្សេងទៀត មិនថាតាមគំរូថវិកាស្ម័គ្រចិត្ត ឬក៏គំរូថវិកាត្រូវបង់ទេ គឺសុទ្ធតែបានបង្ហាញឱ្យឃើញថា តុលាការផ្សេងទៀតទាំងនោះទទួលរងបញ្ហាស្រដៀងគ្នានេះដែរ។ តាមពិត រដ្ឋជាច្រើន មិនបានបង់ចំណែកថវិការបស់ខ្លួនឱ្យទាន់ពេលវេលា ហើយសមាជិកខ្លះនៅសភាភាគីរដ្ឋ នៅតុលាការព្រហ្មទណ្ឌអន្តរជាតិ មិនបានបង់ថវិកាទាន់ពេលរហូតដល់បាត់បង់សិទ្ធិនៅសភានេះផង។ ហេតុនេះ សេណារីយ៉ូបច្ចុប្បន្ននេះនៅ អ.វ.ត.ក គឺគ្មានអ្វីខុសធម្មតាទេនៅក្នុងបរិបទទូទៅនៃសាលាក្ដីព្រហ្មទណ្ឌអន្តរជាតិ[21]។

ង. មិនមានលក្ខខណ្ឌតម្រូវផ្នែកច្បាប់ដើម្បីឱ្យ អ.ស.ប រាជរដ្ឋាភិបាលកម្ពុជា ឬប្រទេសផ្ដល់ជំនួយសំខាន់ៗ ត្រូវធានាផ្ដល់ថវិកាឱ្យ អ.វ.ត.ក សម្រាប់អាយុកាលរបស់តុលាការទេ[22]។

---

[redacted]

ច. ដោយសារក្របខណ្ឌថវិការៀងខ្លួនរបស់ អ.ស.ប និងសមាជិកនៃក្រុមប្រទេសផ្តល់ជំនួយសំខាន់ៗ ទើបមិនអាចចេញការធានាផ្តល់ថវិកាសម្រាប់អាយុកាលទាំងមូលរបស់តុលាការបានទេ[23]។

ឆ. ការប្រើប្រាស់ការកំណត់ថវិកាផ្អែកតាមលទ្ធផល ម្យ៉ាង គឺតម្រូវឱ្យមានយោងតាមវិធានរបស់ អ.ស.ប ដោយសារមានការប្រើប្រាស់ថវិកាឧបត្ថម្ភធនជាដដែលៗ[24] ហើយម្យ៉ាងទៀត ការប្រើប្រាស់វិធីនេះមិនមានគោលបំណងធ្វើឱ្យមានឥទ្ធិពលដោយផ្ទាល់មកលើសេចក្តីសម្រេចលើការផ្តល់ថវិកានាពេលអនាគតទេ[25]។

ជ. ជាពិសេស ក្រុមប្រទេសផ្តល់ជំនួយសំខាន់ៗបានបង្ហាញ"សេចក្តីសោកស្តាយ"ចំពោះការលើកឡើងនៅក្នុងសំណើដែលថាតាមរយៈការផ្តល់ថវិការបស់ខ្លួន ក្រុមប្រទេសម្ចាស់ជំនួយសំខាន់ៗ បានព្យាយាមធ្វើឱ្យមានឥទ្ធិពលមកលើលទ្ធផលនៃសំណុំរឿង ០០៣ សំណុំរឿង ០០៤ និងសំណុំរឿង ០០៤/២[26]។

ឈ. ការិយាល័យរដ្ឋបាល ពន្យល់ថា បច្ចុប្បន្ននេះ អ.ស.ប និង ក្រុមប្រទេសផ្តល់ជំនួយសំខាន់ៗ មិនពិចារណាយុទ្ធសាស្ត្រច្រកចេញឡើយ[27]។

ញ. ចុងក្រោយ ក្រុមប្រទេសផ្តល់ជំនួយសំខាន់ៗ បញ្ជាក់ជាដដែលៗថា ខ្លួននៅតែ"ប្តេជ្ញាចិត្តយ៉ាងមុតមាំ"ដើម្បីធានាឱ្យមានថវិកាសម្រាប់ អ.វ.ត.ក[28]។

---

[redacted]

៨. យើងនឹងដោះស្រាយបញ្ហាទាំងនេះឱ្យបានខ្លីតាមការចាំបាច់។ នៅក្នុងចម្លើយតបរបស់ការិយាល័យរដ្ឋបាល ក៏មានការបញ្ជាក់មិនត្រឹមត្រូវផងដែរទាក់ទងនឹងដំណើរការជ្រើសរើសបុគ្គលិក ដែលនឹងត្រូវដោះស្រាយនៅខាងក្រោម។

៩. មេធាវីការពារក្តី យឹម ទិត្យ បានដាក់សេចក្តីជូនដំណឹងចំនួនពីរដោយមានព័ត៌មានទាក់ទងនឹងស្ថានភាពថវិកា ដែលខ្លួនយល់ឃើញថាពាក់ព័ន្ធនឹងបញ្ហានានាដែលបានលើកឡើងនៅក្នុងសំណើ[29]។ ដោយមូលហេតុដើម្បីសន្សំសំចៃផ្នែកធនធានតុលាការ ទើបចំណុចទាំងនេះនឹងត្រូវដោះស្រាយនៅក្នុងដីកាសម្រេចនេះ ហើយមិនដោះស្រាយនៅក្នុងដីកាសម្រេចដាច់ដោយឡែកសម្រាប់សំណុំរឿង ០០៤ ទេ។

## ៣. ពិភាក្សា

### ក. បញ្ហាបឋម៖ ការបែកធ្លាយសំណើ និងការចេញផ្សាយនៅក្នុងប្រព័ន្ធផ្សព្វផ្សាយ

១០. សំណើត្រូវបានធ្វើឡើងដោយមានគោលបំណងច្បាស់លាស់តាមអ្វីដែលចំណងជើងនៃសំណើបានបញ្ជាក់រួចហើយ ដូចជា ការប៉ុនប៉ងចង់ទទួលបានការបញ្ជាក់ជាលាយលក្ខណ៍អក្សរជាពិសេសពីភាគីពាក់ព័ន្ធនៅក្នុងសហគមន៍ប្រទេសផ្តល់ថវិកា ពីព្រោះថា ជាធម្មតា ព័ត៌មានបែបនេះបញ្ជូនបន្តដោយផ្ទាល់មាត់នៅក្នុងអង្គប្រជុំនានា ឧទាហរណ៍ ដូចបានលើកឡើងដោយ

[redacted]

ការិយាល័យរដ្ឋបាលនៅក្នុងសារណារបស់ខ្លួន[30] ដោយកំណត់ហេតុអង្គប្រជុំទាំងនេះត្រូវរៀបចំឡើងដោយការិយាល័យរដ្ឋបាល ជាឯកសារសម្ងាត់។

១១. នៅក្នុងសំណើ[31] មានការលើកឡើងថា ពេលកន្លងមកជាបន្តបន្ទាប់ ស.ច.ស បានបង្ហាញសេចក្តីព្រួយបារម្ភរបស់ខ្លួនជូនទៅសមាជិកនៃក្រុមប្រទេសផ្តល់ជំនួយសំខាន់ៗ តាមវិធីផ្សេងៗ រួមមាន អ្នកជំនាញពិសេសរបស់អគ្គលេខាធិការ ហើយពិតណាស់ ស.ច.ស នៅតែទាក់ទងយ៉ាងជិតស្និទ្ធជាបន្តបន្ទាប់ជាមួយសមភាគីរបស់ខ្លួននៅការិយាល័យរដ្ឋបាល អំពីផលប៉ះពាល់ជាសក្តានុពលដោយសារបញ្ហាថវិកាក្នុងករណីដែលបញ្ហាថវិកាកើតឡើង។ ស្រដៀងគ្នានេះដែរ ខ្លឹមសារនៃរបាយការណ៍បញ្ចប់ការងារប្រចាំត្រីមាស ត្រូវបានធ្វើឡើងដោយមានការចូលរួមចំណែកពីចៅក្រមនៅផ្នែកផ្សេងៗ ហើយមានតែសំណៅស្ពាពរនៃរបាយការណ៍ទាំងនោះតែប៉ុណ្ណោះដែលត្រូវកែសម្រួលដោយការិយាល័យរដ្ឋបាល។ នៅក្នុងបរិបទបែបនេះ មានលំហូរជាអចិន្ត្រៃយ៍នូវការសន្ទនាគ្នាអំពីតារាងពេលវេលា សមិទ្ធផលសំខាន់ៗ ។ល។ ប៉ុន្តែ ដូចយើងនឹងធ្វើការពន្យល់នៅពេលក្រោយនៅខាងក្រោមនេះដែរ ចំពោះយើងហាក់ដូចជាថា លក្ខណៈនៃព័ត៌មានដែលយើងទទួលបានពីប្រភពមួយចំនួននៅមូលដ្ឋានផ្ទាល់ គឺមិនមានលក្ខណៈដូចគ្នាទាំងស្រុងទេដូចពីមុនដែរ ហើយការយល់ឃើញរបស់ អ.ស.ប និងក្រុមប្រទេសផ្តល់ជំនួយសំខាន់ៗនៅអាសនៈទីស្នាក់ការ អ.ស.ប ឬក៏សូម្បីតែការយល់ឃើញរបស់តំណាងការទូតប្រចាំប្រទេស ក៏មិនមានលក្ខណៈដូចគ្នាទាំងស្រុងដែរ។

១២. ជាងនេះទៀត មិនមានមូលដ្ឋានទេនៅក្នុងការសន្មតដែលថា ស.ច.ស គួរតែបានឱ្យសាធារណជនទូទៅ ឬ"សង្គមស៊ីវិល"ចូលរួមតស៊ូមតិនេះ[32] ហើយការមិនបានធ្វើដូច្នេះគឺជា"ការ

30 [redacted]

31 [redacted]

32 "ទីមួយ មិនមានមូលដ្ឋានសមហេតុផលដែលចៅក្រមដាក់ឯកសារទៅផ្នែកសម្ងាត់ដែលការពារយុទ្ធសាស្ត្រស៊ើបសួរ និងកិច្ចស៊ើបសួរពេញច្បាប់។ ចៅក្រមដឹងច្បាស់ថា សេចក្តីព្រួយបារម្ភអំពីថវិកា គឺជា"មូលដ្ឋានតែមួយគត់"សម្រាប់វិធានការដែលខ្លួនបានពិចារណា ហើយមិនជាប់ពាក់ព័ន្ធ ឬក៏អាស្រ័យលើអង្គហេតុ ឬការពិចារណាលើរឿងក្តីណាមួយឡើយ។ នេះគឺជាបញ្ហារដ្ឋបាល និងនយោបាយដែលសង្គមស៊ីវិល និងប្រជាជនកម្ពុជា មានសិទ្ធិត្រូវយល់ដឹង បញ្ចេញមតិយោបល់ ហើយប្រហែលជាចូលរួមដោះស្រាយ។ ការលើកឡើងជាសាធារណៈដែលថា ឪសានវាទ និងឯកសាររបស់ចៅក្រម នាំឱ្យមាន

បដិសេធដំណើរការនីតិវិធីត្រឹមត្រូវ"។ តាមការយល់ឃើញរបស់យើង វាមិនសមហេតុផលដែលផ្តល់ទឡ្ហីករណ៍ថា ចំពោះបញ្ហាដំណើរការនីតិវិធីត្រឹមត្រូវ ចៅក្រមគួរតែបញ្ជូនដំណើររឿងនៃកិច្ចដំណើរការនីតិវិធីទៅក្នុងសំណុំរឿងណាមួយទៀតស្ទើមតិជាសាធារណៈ ឬក៏អាចធ្វើប្រជាមតិទៀតផង ជាពិសេសប្រសិនបើបញ្ហាបែបនេះកើតឡើងនៅក្នុងផ្នែកសម្ងាត់នៃកិច្ចដំណើរការនីតិវិធី។ ចំពោះសេចក្តីសម្រេចរបស់ខ្លួន ចៅក្រមទទួលខុសត្រូវចំពោះផលប្រយោជន៍សាធារណៈតាមរយៈតុលាការជាន់ខ្ពស់ ហើយចំពោះការប្រព្រឹត្តិរបស់ខ្លួនក្នុងការបំពេញការងារវិញ គឺទទួលខុសត្រូវតាមរយៈតុលាការវិន័យ ឬតុលាការព្រហ្មទណ្ឌទូទៅដែលបង្កើតឡើងតាមលក្ខន្តិកៈច្បាប់ពាក់ព័ន្ធរបស់ប្រទេសណាមួយដែលស្ថិតនៅក្រោមនីតិរដ្ឋ ដើម្បីអនុវត្តការត្រួតពិនិត្យផ្នែកតុលាការក្នុងរបៀបប្រជាធិបតេយ្យពេញច្បាប់ពីសំណាក់រដ្ឋ ហើយតាមរយៈរដ្ឋ គឺអនុវត្តការត្រួតពិនិត្យផ្នែកតុលាការបែបនេះពីសំណាក់ពលរដ្ឋ។ ជាងនេះទៀត ជាក់ស្តែង ការត្រួតពិនិត្យយ៉ាងសមហេតុផល គឺត្រូវអនុវត្តដោយប្រព័ន្ធផ្សព្វផ្សាយ ឱ្យតែប្រព័ន្ធផ្សព្វផ្សាយខិតខំប្រឹងប្រែងគ្រប់បែបយ៉ាងដើម្បីទទួលបានអង្គហេតុសុក្រឹត ហើយស្វែងយល់ឱ្យបានត្រឹមត្រូវអំពីមូលដ្ឋានគ្រឹះនៃកិច្ចដំណើរការនីតិវិធីតុលាការ ដើម្បីបញ្ចេញទស្សនៈយល់ឃើញរបស់ខ្លួន និងមុនពេលបញ្ចេញទស្សនៈយល់ឃើញរបស់ខ្លួន។

១៣. នេះរាប់បញ្ចូលទាំងការគោរពតាមចៅក្រម ចំពោះការធ្វើចំណាត់ថ្នាក់ឯកសារលើសេចក្តីសម្រេចនានា ជាឯកសារសម្ងាត់។ ក្រៅពីក្របខណ្ឌនេះ សង្គមស៊ីវិល ប្រព័ន្ធផ្សព្វផ្សាយ និងសាធារណជន មិនមានសិទ្ធិទូទៅសំខាន់ជាងនេះត្រូវទទួលបានព័ត៌មានឱ្យហួសពីអ្វីដែលចៅក្រមមានសមត្ថកិច្ចបានសម្រេចដាក់បង្ហាញឡើយ។ ការពិតដែលថា ការបែកធ្លាយទាំងមិនស្របច្បាប់អំពីព័ត៌មានសម្ងាត់នៅ អ.វ.ត.ក បានកើតឡើងជាទូទៅនាពេលកន្លងមក ហើយស្ទើរតែគ្មានការដាក់ទោសនោះ គឺមិនមែនជាយុត្តិកម្មឱ្យបន្តការអនុវត្តគួរឱ្យអាម៉ាស់បែបនេះទៀតទេ។ ដូចបានបញ្ជាក់នៅក្នុងករណីអន្តរជាតិពាក់ព័ន្ធនឹងការរំលោភលើគោលការណ៍រក្សាការសម្ងាត់របស់តុលាការ បុគ្គលនានា រាប់បញ្ចូលទាំងអ្នកសារព័ត៌មានផងដែរ មិនអាចផ្សព្វ

---

"បញ្ហារសើប ហើយមិនបានពិភាក្សាឱ្យបានត្រឹមត្រូវនៅក្នុងមជ្ឈដ្ឋានសាធារណៈនៅសំណាក់កាលនេះ" គឺជាមើលងាយដល់សង្គមស៊ីវិលដែលបានខិតខំធ្វើការដើម្បីគាំទ្រគោលដៅរបស់តុលាការ និងប្រជាជនកម្ពុជា ជាទូទៅ។ នេះគឺជាការប្រើប្រាស់មិនត្រឹមត្រូវនូវវិធានរក្សាការសម្ងាត់ដែលគ្រប់គ្រងតុលាការ" សូមមើល https://www.opensocietyfoundations.org/briefing-papers/recent-developments-extraordinary-chambers-courts-cambodia-june-2017 ទំព័រ ៣ [ភាសាអង់គ្លេស]។

01522529



ផ្សាយដោយគ្មានទោសអំពីព័ត៌មានដែលចៅក្រមចាត់ទុកថាជាព័ត៌មានសម្ងាត់ ផ្អែកលើមូលដ្ឋាននៃការវាយតម្លៃផ្ទាល់ខ្លួនរបស់ចៅក្រមទៅលើផលប្រយោជន៍សាធារណៈនៅក្នុងព័ត៌មាននោះ[33]។ ទង្វើបែបនេះអាចធ្វើឱ្យគ្រោះថ្នាក់ដល់សុចរិតភាពនៃកិច្ចដំណើរការនីតិវិធី ហើយកាត់បន្ថយការទុកចិត្តរបស់សាធារណជនមកលើសមត្ថភាពរបស់តុលាការក្នុងការរក្សាការសម្ងាត់[34]។ កិច្ចសហការពីបុគ្គល អង្គការ និងរដ្ឋនានា គឺមានសារៈសំខាន់ដើម្បីឱ្យសាលាក្តីព្រហ្មទណ្ឌអន្តរជាតិដំណើរការទៅបានយ៉ាងត្រឹមត្រូវ។ ការរំលោភលើគោលការណ៍រក្សាការសម្ងាត់ ដែលធ្វើឱ្យប៉ះពាល់ដល់ការទុកចិត្តមកលើសមត្ថភាពរបស់តុលាការក្នុងការរក្សាការសម្ងាត់ គឺបំផ្លាញកិច្ចសហការបែបនេះ ហេតុនេះ ត្រូវតែដាក់ទោស។

១៤. ម្យ៉ាង ការលើកឡើងដែលថា បញ្ហាថវិកានេះគឺជាបញ្ហា“រដ្ឋបាលសុទ្ធសាធ” ហេតុនេះគួរតែបានផ្សព្វផ្សាយជាសាធារណៈនោះ គឺជាឧទាហរណ៍មួយអំពីការប្រើប្រាស់ពាក្យពេចន៍ធូររលុងទេ- បញ្ហាការងារបុគ្គលិករបស់តុលាការក៏មានលក្ខណៈរដ្ឋបាលផងដែរ ប៉ុន្តែជាការសម្ងាត់យ៉ាងច្បាស់។ ប៉ុន្តែ ម្យ៉ាងទៀត ការលើកឡើងបែបនេះមិនគិតពីការពិតដ៏សាមញ្ញដែលថា បញ្ហានានាដូចជា បញ្ហាកង្វះថវិកាកើតឡើងជាដដែលៗ គឺជាបញ្ហារសើបខ្លាំងផ្នែកនយោបាយ ហើយគួរតែដោះស្រាយក្នុងរបៀបមួយដែលអាចឱ្យមានការសន្ទនាគ្នាប្រកបដោយស្ថាបនា ដើម្បីស្វែងរកដំណោះស្រាយ។ គោលបំណងរបស់យើងនៅពេលនោះគឺលើកទឹកចិត្តឱ្យម្ចាស់ជំនួយ ផ្តល់ថវិកាឱ្យបានគ្រប់គ្រាន់ មិនមែនចង់ឱ្យម្ចាស់ជំនួយស្ថិតនៅក្នុងចំណាប់អារម្មណ៍សាធារណៈ ដោយបង្ហាញឈ្មោះម្ចាស់ជំនួយ និងឱ្យម្ចាស់ជំនួយអាម៉ាស់ជាសាធារណៈនោះឡើយ។ ការបែកធ្លាយនូវសំណើ ហើយបន្ទាប់មកមានការប៉ាន់ស្មាននៅក្នុងប្រព័ន្ធផ្សព្វផ្សាយអំពីការងារតុលាការមិនបានល្អនោះ គឺសុទ្ធតែមានសក្តានុពលអាចបំផ្លាញបរិយាកាសស្ថាបនាបែបនោះ។ ចុងក្រោយ យើងមិនយល់ស្របថា បញ្ហាដែលបានលើកឡើងនៅក្នុងសំណើ មានលក្ខណៈជាបញ្ហារដ្ឋបាលសុទ្ធសាធទេ។ ការលើកឡើងថាជាបញ្ហារដ្ឋបាលសុទ្ធសាធនោះ គឺមិនបានមើលឃើញពីតួនាទីជាសារវន្តរបស់ចៅក្រមនៅក្នុងកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌ។ ជាគោលការណ៍ យន្តការផ្តល់ហិរញ្ញវត្ថុ គឺជាបញ្ហារដ្ឋបាល ប៉ុន្តែ កង្វះ

---

[33] រឿងក្តី *Re Hartmann* សាលដីកា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី( IT-02-54-R77.5-A) ថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ២០១១ កថាខណ្ឌ ៥២, ៧១។

[34] ដូចជើងទំព័រខាងលើ កថាខណ្ឌ ៧៤។

ចរិការអាចរំលោភលើដំណើរការប្រព្រឹត្តទៅ ខ្លឹមសារ ភាពយុត្តិធម៌ និងសុចរិតភាពនៃកិច្ចដំណើរការនីតិវិធី។ នៅពេលបញ្ហានេះកើតឡើង ឬអាចនឹងកើតឡើង បញ្ហាទាំងនេះលែងជាបញ្ហារដ្ឋបាលសុទ្ធសាធទៀតហើយ ហើយនាំឱ្យស្ថាប័នតុលាការមានសមត្ថកិច្ច ត្រូវទទួលខុសត្រូវចាត់វិធានការទាំងនោះដែលចាំបាច់ដើម្បីបញ្ចៀសកុំឱ្យមានភាពអយុត្តិធម៌។

១៥. ដោយសារឥឡូវនេះដំណើរការដាក់មតិយោបល់ឆ្លើយតបបានចប់សព្វគ្រប់ហើយ យើងនឹងចេញសំណៅសាធារណៈដោយមានការកោសលុបនៃដីកាសម្រេចនេះ។ ប៉ុន្តែ យើងនឹងលែងអត់ឱនទៀតហើយចំពោះករណីមិនគោរពតាមដីកាតុលាការណាដែលត្រូវបានចាត់ទុកថាជាការសម្ងាត់ ហេតុនេះសូមជូនដំណឹង ភាគី និងការិយាល័យរដ្ឋបាល ព្រមទាំងមនុស្សទាំងអស់នៅ អ.វ.ត.ក ដែលអាចមានសិទ្ធិស្របច្បាប់ចូលមើលសំណៅសម្ងាត់ ឱ្យបានដឹងថា យើងចាត់ទុកថា ការដាក់បង្ហាញអត្ថបទ ឬខ្លឹមសារផ្នែកសម្ងាត់ទាំងអស់នៃដីកាសម្រេចនេះ និងដីកាសម្រេចសម្ងាត់ផ្សេងទៀតនាពេលអនាគត ទោះថាធ្វើឡើងដោយភាគី ឬបុគ្គលិករបស់ អ.វ.ត.ក ឬប្រព័ន្ធផ្សព្វផ្សាយក៏ដោយ ក៏ជាការរំលោភលើវិធានផ្ទៃក្នុង ៣៥(១)(ក) ហើយយើងនឹងចាត់វិធានការលើបទល្មើសណាមួយនាពេលអនាគត យោងតាមវិធានផ្ទៃក្នុង ៣៥(២) និង(៤) ដោយភ្ជាប់ជាមួយនឹងមាត្រា ៣១៤ នៃក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ២០០៩ ហើយនឹងចាត់វិធានការផ្សេងទៀតតាមការចាំបាច់។

**ខ. អំណាចចេញដីកាសម្រេចផ្អាកកិច្ចដំណើរការនីតិវិធី**

១៦. យើងបានធ្វើការសិក្សាយ៉ាងច្រើនអំពីច្បាប់ទាក់ទងនឹងការផ្អាកកិច្ចដំណើរការនីតិវិធី ទាំងច្បាប់ជាតិ ទាំងច្បាប់អន្តរជាតិ។ យើងជឿថា ទាំងច្បាប់កម្ពុជា ទាំងច្បាប់អន្តរជាតិ មានចែងអំពីសេណារីយ៉ូដែលសមស្របឱ្យចេញដីកាបែបនេះ។ តាមពិត ស.ព.អ ក៏ទទួលស្គាល់បានច្រើនបែបនេះផងដែរនៅពេលដែលគាត់យោងលើសេចក្តីសម្រេចមួយរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ អំពីបញ្ហានេះ[35]។ យើងមិនបានចេញសំណើទេ ប្រសិនបើការយល់ឃើញរបស់យើងនៅមានមន្ទិលអំពីបញ្ហានេះនោះ។ ជាធម្មតា ការយល់ឃើញផ្សេងគ្នា អាចខ្វែងគំនិតគ្នា

35 [redacted]

លើបញ្ហាចោទថាតើអង្គហេតុទាំងនេះធ្ងន់ធ្ងរហួតដល់តម្រូវឱ្យមានវិធានការធ្ងន់ធ្ងរចេញដីកាបែបនេះដែរឬអត់។ ដោយសារចេញដីកាសម្រេចនេះហើយ ទើបយើងយល់ឃើញថាមិនចាំបាច់ពិចារណាលើបញ្ហានេះទេនៅដំណាក់កាលនេះ[36]។

**គ. គ្មានអំណាចសម្រេចលើកាតព្វកិច្ចហិរញ្ញវត្ថុរបស់ អ.ស.ប ក្រុមប្រទេសផ្តល់ជំនួយសំខាន់ៗ ឬរាជរដ្ឋាភិបាលកម្ពុជា ស.ច.ស គួរប្រកាន់ខ្ជាប់នូវការបំពេញកិច្ចស៊ើបសួររបស់ខ្លួន ហើយសម្រេចរឿងក្តីដោយផ្អែកលើអង្គច្បាប់**

១៧. ទឡ្ហីករណ៍នេះគឺជាបញ្ហាក្តៅគគុក។ យើងមិនដែលប្រកាន់ថា យើងមានយុត្តាធិការលើផ្នែកហិរញ្ញវត្ថុទេ ប៉ុន្តែ ច្បាស់បំផុតណាស់គឺថា យើងពិតជាមានយុត្តាធិការពិចារណាសម្រេចលើផលប៉ះពាល់ដែលស្ថានភាពហិរញ្ញវត្ថុ អាចមានមកលើភាពយុត្តិធម៌នៃកិច្ចដំណើរការនីតិវិធី។ ឧទាហរណ៍ដ៏សាមញ្ញមួយអាចបញ្ជាក់ពីភាពខុសគ្នានេះ៖ ប្រសិនបើម្ចាស់ជំនួយជូនដំណឹងតុលាការនៅថ្ងៃស្អែកថា ម្ចាស់ជំនួយនឹងលែងបង់ថវិកាសម្រាប់សំណុំរឿង 00៣ សំណុំរឿង 00៤ និងសំណុំរឿង 00៤/២ ទៀតហើយ នោះ យើងនឹងមិនមានអំណាចចេញដីកាបង្គាប់ឱ្យម្ចាស់ជំនួយ ត្រូវបង់ថវិកានេះឡើយ មិននិយាយដល់ការអនុវត្តដីកាបែបនេះផង។ ប៉ុន្តែ យើងមានអំណាចបញ្ឈប់ការស៊ើបសួរទាំងអស់ ដោយសារមានការរំលោភបំពានជាសារវ័ន្តលើសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ និងជាក់ស្តែង ដោយសារការបំបាត់ចោលការិយាល័យរបស់យើងក្នុងនាមជា ស.ច.ស។ ជាងនេះទៀត ការលើកឡើងអំពី "អង្គច្បាប់" ហាក់ដូចជាមិនបានគិតពីការយល់ឃើញយ៉ាងតិចតួចសោះអំពីអាណត្តិរបស់យើងក្នុងនាមជាចៅក្រម គឺហាក់ដូចជាថា អាណត្តិការងារនេះគ្រាន់តែទាក់ទងនឹងការសម្រេចថាតើជនត្រូវ

[36] យើងកត់សម្គាល់ថា ស.ព.អ (នៅជើងទំព័រ ៤៣) ដកស្រង់អត្ថបទមួយពីសៀវភៅរបស់ ស.ច.ស. អន្តរជាតិដើម្បីគាំទ្រសេចក្តីសន្និដ្ឋានផ្ទាល់ខ្លួនរបស់គាត់។ ក្រៅពីអង្គហេតុដែលថា អត្ថបទនេះពាក់ព័ន្ធនឹងច្បាប់អាល្លឺម៉ង់ ជាការល្អប្រសើរប្រសិនបើ ស.ព.អ បានស្វែងយល់ផងដែរអំពីករណីយុត្តិសាស្ត្រដែលបានដកស្រង់នៅទំព័រខាងក្រោយ ដែលយោងយ៉ាងច្បាស់លើទស្សនទានអំពីការផ្អាកកិច្ចដំណើរការនីតិវិធីទាក់ទងនឹង"ការមិនបានបំពេញតាមនីតិវិធី" និងការវិវត្តនៃយុត្តិសាស្ត្រអំពីជនញុះញង់ ជាពិសេស។ ប្រសិនបើបានអានសៀវភៅនេះឱ្យបានលម្អិតថែមទៀត(នៅទំព័រ ១៨៨-១៨៩) នោះនឹងបានបង្ហាញឱ្យឃើញថា នាពេលថ្មីៗនេះ ចុងក្រោយបំផុតនៅឆ្នាំ ២00៩ នៅក្នុងបរិបទនៃការដាក់ទោស តុលាការធម្មនុញ្ញសហព័ន្ធ បានសម្រេចថា ក្នុងករណីធ្ងន់ធ្ងរមានការរំលោភលើសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ ដែលមានចែងនៅអនុសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្ស ច្បាប់ធម្មនុញ្ញអាល្លឺម៉ង់ អាចតម្រូវឱ្យឈប់បន្ត ឬក៏បញ្ឈប់កិច្ចដំណើរការនីតិវិធី។

ចោទទទួលខុសត្រូវតាមបទប្បញ្ញត្តិនៃច្បាប់សារធាតុដែរ ឬអត់តែប៉ុណ្ណោះ។ ជាទូទៅ ចំពោះបញ្ហាចរិកាបែបនេះ វាច្បាស់ជាបញ្ហាអង្គច្បាប់នៅក្នុងចំណោម"ប្រទេសស៊ីវិល័យ" តាមអត្ថន័យនៃមាត្រា ៣៨(១)(ឃ) នៃលក្ខន្តិកៈតុលាការយុត្តិធម៌អន្តរជាតិ ដោយសារឥឡូវនេះចៅក្រមក៏ត្រូវតែធានាឱ្យមានការគោរពតាមវិធានការការពារនីតិវិធីនៅក្នុងកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌផងដែរ[37]។

## ឃ. សេចក្តីព្រួយបារម្ភផ្នែកហិរញ្ញវត្ថុដែលហួសពីដំណាក់កាលស៊ើបសួរ គឺជាសេចក្តីព្រួយបារម្ភសម្រាប់អង្គជំនុំជម្រះក្រោយពីចេញដីកាដំណោះស្រាយ

១៨. យើងបានបង្ហាញការយល់ឃើញផ្សេងៗរបស់យើងអំពីចំណុចនេះយ៉ាងច្បាស់ណាស់នៅក្នុងសំណើ ហើយយើងសូមយោងលើផ្នែកដែលពាក់ព័ន្ធនៅក្នុងសំណើ[38]។ ប៉ុន្តែ ជារឿងធម្មតាទេដែលថា វាពិតជាករណីមួយសម្រាប់សហសេវិកចៅក្រមរបស់យើងនៅក្នុងអង្គជំនុំជម្រះដែលត្រូវការពារវិធានការការពារនីតិវិធីឱ្យជនត្រូវចោទ/ជនជាប់ចោទ នៅពេលដែលយើង*ស័រងមានភារកិច្ចបន្ទាប់ពីចេញដីកាដំណោះស្រាយចុងក្រោយ* មិនថាបញ្ជូនទៅជំនុំជម្រះ ឬក៏លើកលែងការចោទប្រកាន់នោះទេ។ សហសេវិកចៅក្រមអាចឯកភាពតាមយើង ឬអាចមិនឯកភាពតាមយើង- បែបនេះគឺជាលក្ខណៈការងារតាមការិយាល័យតុលាការ។

## ង. មិនមានវិបត្តិហិរញ្ញវត្ថុ ហើយ ស.ច.ស មិនបានផ្តល់សំអាងហេតុ ឬការវិភាគលម្អិតអំពីសេចក្តីព្រួយបារម្ភរបស់ខ្លួន

១៩. ចំពោះយើង បង្ហាញឱ្យឃើញច្បាស់ថា យ៉ាងហោចណាស់ប្រាកដជាមានដំណើររឿងពីរខុសគ្នាអំពីស្ថានភាពចរិកានេះ ដំណើររឿងមួយបង្ហាញជូនយើងពីការិយាល័យរដ្ឋបាល និងអ្នក

---

[37] ចំណុចនេះមានចែងយ៉ាងច្បាស់នៅមាត្រា ២៣ ថ្មីនៃច្បាប់ អ.វ.ត.ក ដែលផ្តល់ជូន ស.ច.ស នូវការទទួលខុសត្រូវលើការស៊ើបអង្កេត។ មាត្រា ៣៥ ថ្មី នៃច្បាប់ អ.វ.ត.ក(ដែលអាចអនុវត្តបានផងដែរទៅដំណាក់កាលស៊ើបអង្កេតនៃកិច្ចដំណើរការនីតិវិធី) ចែងឡើងវិញអំពីសិទ្ធិជាសារវ័ន្តរបស់ជនត្រូវចោទ ដែលមានចែងនៅមាត្រា ១៤ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។ ស្រដៀងគ្នានេះដែរ វិធានផ្ទៃក្នុង ២១ ចែងអំពីសិទ្ធិដែលអាចអនុវត្តបានជាអាទិ៍ សិទ្ធិដែលអាចអនុវត្តបានចំពោះជនត្រូវចោទស្ថិតនៅក្រោមការស៊ើបអង្កេតរបស់តុលាការនៅ អ.វ.ត.ក។ វាជាការពិតជាក់ស្តែងដោយស្វ័យប្រវត្តិដែលថា ការទទួលខុសត្រូវយោងតាមមាត្រា ២៣ ថ្មី នៃច្បាប់ អ.វ.ត.ក គឺបញ្ចូលទាំងការធានាឱ្យគោរពសិទ្ធិជាសារវ័ន្តទាំងនេះ។

[38] [redacted]

ជំនាញ ពិសេសរបស់អគ្គលេខាធិការ ហើយដំណើររឿងមួយទៀតដែលហាក់ដូចជាដឹងជាទូទៅនៅក្នុងគណៈកម្មាធិការនាយករបស់ក្រុមប្រទេសផ្តល់ជំនួយសំខាន់ៗនៅអាសនៈទីស្នាក់ការ អ.ស.ប។ ដំណើររឿងទាំងពីរនេះបង្ហាញឱ្យឃើញថាមិនស៊ីសង្វាក់គ្នា ហើយមធ្យោបាយនៃការជូនដំណឹងគ្នាទៅវិញទៅមក អាចមិនបានបើកជំហរឱ្យបានពេញលេញផងដែរ ដូចដែលបានបង្ហាញតាមរយៈការសន្ទនាម្តងម្កាលរបស់យើងជាមួយនឹងអ្នកការទូតប្រចាំប្រទេសមកពីសមាជិកនៃក្រុមប្រទេសផ្តល់ជំនួយសំខាន់ៗដែលមកទស្សនកិច្ចនៅតុលាការ ពីព្រោះថាអ្នកការទូតទាំងនោះក៏មិនបានដឹងអំពីភាពខុសគ្នានេះដែរ។ ដូចដែលយើងបានពន្យល់នៅខាងលើដែរ យើងនៅបន្តធ្វើការសន្ទនាជាបន្តបន្ទាប់ជាមួយការិយាល័យរដ្ឋបាល ហើយចំពោះអ្នកជំនាញពិសេសរបស់អគ្គលេខាធិការវិញ យើងនៅតែបន្តធ្វើការសន្ទនាជាបន្តបន្ទាប់ជាមួយគាត់ផងដែរនៅពេលដែលគាត់ចុះមកទស្សនកិច្ចនៅតុលាការជាទៀងទាត់ និងនៅចន្លោះពេលនៃដំណើរទស្សនកិច្ចទាំងនោះ ។

២០. សារដែលបានបញ្ជូនមកយើងពីប្រភពទាំងនេះ គឺគួរឱ្យភ្ញាក់ផ្អើលគ្រប់គ្រាន់ឱ្យយើងចាត់វិធានការខ្លាំងដែលត្រូវចេញសំណើ។ ពីមុន និងពេលឥឡូវនេះ យើងមិនបានឃើញថាមានមូលហេតុត្រូវគិតថា ប្រភពណាមួយក្នុងចំណោមប្រភពព័ត៌មានទាំងនេះនឹងបង្ហាញជូនយើងនូវព័ត៌មានមិនល្អដោយគ្មានហេតុផលល្អនោះទេ ដោយពិនិត្យលើបញ្ហាពាក់ព័ន្ធនានាសម្រាប់ចក្ខុវិស័យទៅមុខនៃកិច្ចដំណើរការនីតិវិធី ហេតុនេះ យើងបានបន្តនីតិវិធីដោយសន្មតថា ប្រភពទាំងនេះផ្តល់ព័ត៌មានដែលទទួលបានតាមរយៈមធ្យោបាយនៃការជូនដំណឹងជាផ្លូវការរបស់ខ្លួន ហើយពឹងផ្អែកការវាយតម្លៃរបស់ខ្លួនទៅលើព័ត៌មានទាំងនោះ និងបទពិសោធន៍ដ៏ច្រើនរបស់ខ្លួនអំពីការវិវត្តរបស់ អ.វ.ត.ក។

២១. ដូចដែលយើងនឹងបង្ហាញខាងក្រោមនេះដែរ ការិយាល័យរដ្ឋបាល និង អ.ស.ប ត្រូវបានជូនដំណឹងអំពីការវិវត្តដែលអាចកើតឡើងនេះចាប់តាំងពីខែ តុលា ឆ្នាំ ២០១៦ មកម្លេះ ហើយយើងសន្មតថា តាមរយៈ អ.ស.ប ក្រុមប្រទេសផ្តល់ជំនួយសំខាន់ៗក៏ទទួលបានដំណឹងបែបនេះផងដែរ។

២២. មិនគួរទាល់តែសោះដែលឥឡូវនេះ យើងត្រូវតែយោងលើខ្លឹមសារនៃការប្រាស្រ័យទាក់ទងគ្នាជាមួយប្រភពនីមួយៗទាំងនោះ ប៉ុន្តែ យើងគ្មានជម្រើសទេ ដោយសារថា អ.ស.ប និងក្រុម

ប្រទេសផ្តល់ជំនួយសំខាន់ៗ បានធ្វើការចោទប្រកាន់ដោយប្រយោលថា យើងបង្កឱ្យមានការភ័យស្លន់ស្លោដែលមិនចាំបាច់។ នៅក្នុងបរិបទនេះ និងនៅផ្នែកខាងក្រោយទៀតនៅក្នុងដីកាសម្រេចនេះ យើងមិនបានបង្ហាញឡើងវិញនូវការប្រាស្រ័យទាក់ទងគ្នាផ្ទៃក្នុងជាលាយលក្ខណ៍អក្សរជាមួយការិយាល័យរដ្ឋបាល ឱ្យបានលម្អិតទេ។ ក្នុងករណីណាក៏ដោយ ភាគីសំណុំរឿងមិនមានសិទ្ធិចូលពិនិត្យឯកសារទាំងនេះទេ ដោយមិនគិតពីកម្រិតខ្លឹមសារដែលអាចស្ថិតនៅក្រោមឯកសិទ្ធិរបស់ អ.ស.ប ផង។

២៣. នៅថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២០១៦ តាមគំនិតផ្តួចផ្តើមផ្ទាល់ខ្លួន យើងបានចាត់វិធានការ ដែលមិនធ្លាប់មាននៅក្នុងប្រវត្តិរបស់ អ.វ.ត.ក គឺបានលើកឡើងអំពីវិធានការនេះនៅក្នុងអង្គប្រជុំមួយជាមួយអ្នកតំណាងការទូតរបស់ក្រុមប្រទេសផ្តល់ជំនួយសំខាន់ៗនៅស្ថានទូតបារាំងប្រចាំនៅភ្នំពេញ។ នៅក្នុងអង្គប្រជុំរយៈពេលប្រហែលជា ៩០ នាទីនេះ យើងបានព្យាយាមពន្យល់អំពីរចនាសម្ព័ន្ធដែលយើងធ្វើការ ហើយឆ្លើយសំណួរពីក្រុមប្រទេសផ្តល់ជំនួយសំខាន់ៗ ដើម្បីផ្តល់ជាការយល់ឃើញឱ្យបានច្រើនតាមដែលច្បាប់អាចអនុញ្ញាត ក្នុងគោលបំណងកុំឱ្យមានការយល់ច្រឡំ និងជំរុញទឡ្ហីករណ៍របស់យើងដើម្បីឱ្យមានថវិកាគ្រប់គ្រាន់។ យើងបានផ្តល់ជូនអ្នកចូលរួមអង្គប្រជុំនូវឯកសារជាច្រើនដើម្បីបង្ហាញពីចំណុចគោលបំណងរបស់យើង។ ប៉ុន្តែ មតិយោបល់ដំបូងដែលបានបង្ហាញគឺរិះគន់លើល្បឿននៃការស៊ើបសួរ ចំណែកឯមតិមួយទៀតពាក់ព័ន្ធនឹងការទប់ទល់ជាមួយនឹងយុទ្ធសាស្ត្រពន្យារពេលរបស់មេធាវីការពារក្តី ដែលបញ្ហានេះយើងបានជម្រាបអង្គប្រជុំថាមិនមែនជាបញ្ហានៅក្នុងការស៊ើបសួរទេ។ ចុងក្រោយសំណួរមួយទៀតមានបំណងសួរអំពីអ្វីដែលនឹងកើតឡើងប្រសិនបើថវិកាមិនមានគ្រប់គ្រាន់ ឬក៏ឈប់បន្តផ្តល់ថវិកា ហើយយើងបានឆ្លើយតបថា យើងនឹងពិចារណាសេណារីយ៉ូបែបនេះនៅពេលនោះប្រសិនបើបញ្ហានេះកើតឡើងមែន ប៉ុន្តែ សេចក្តីសម្រេចណាមួយដែលធ្វើឡើងមិនអាចប៉ះពាល់ដល់ភាគីការពារក្តីឡើយ។

២៤. កំណត់ហេតុនៃអង្គប្រជុំសហជីពបុគ្គលិកផ្ញើពីមេធាវីការពារក្តី យឹម ទិត្យ នៅថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១៧[39] គឺស្របតាមការសន្ទនាដែល ស.ច.ស.អន្តរជាតិ ("ស.ច.ស.អ") បានធ្វើ

39 [redacted]

ឡើងជាយូរមកហើយជាមួយការិយាល័យរដ្ឋបាល។ កំណត់ហេតុនោះក៏យល់ស្របតាមការបញ្ជាក់ជាទូទៅរបស់ការិយាល័យរដ្ឋបាល ខ្លួនឯងនៅសំណៅលើកទី ១២ នៃរបាយការណ៍បញ្ចប់ការងារប្រចាំត្រីមាស រៀបចំឡើងដោយការិយាល័យរដ្ឋបាល ហើយបានចេញនៅថ្ងៃតែមួយជាមួយនឹងសំណើ៖

> *ការចាកចេញបុគ្គលិកសំខាន់ៗ ឧទាហរណ៍ ដោយសារស្ថានភាពថវិកាទូទៅ ហើយការផិតចប់អាណត្តិរបស់ការិយាល័យ ឬការរៀបចំផែនការអាជីព គឺជាហានិភ័យធ្ងន់ធ្ងរមួយទៀតសម្រាប់ការព្យាករតារាងពេលវេលា [យើងគូសបញ្ជាក់បន្ថែម]*[40] ។

២៥. [redacted]

---

[40] សូមមើល www.eccc.gov.kh/en/eccc-completion-plan-revision-12 ត្រង់កថាខណ្ឌ ២៣។ សូមមើលផងដែរ ដូចជានឹងទំព័រខាងលើ កថាខណ្ឌ ១៨ ដែលបញ្ជាក់ថា ការស៊ើបអង្កេត "ក៏អាស្រ័យផងដែរលើកត្តាផ្សេងដែលស្ថិតនៅក្រៅការគ្រប់គ្រងរបស់ចៅក្រម" ឧទាហរណ៍ ដូចជា ថវិកាគ្រប់គ្រាន់សម្រាប់តំណែងទំនេរ និងនីតិវិធីជ្រើសរើសបុគ្គលិកទាន់ពេលវេលា"។

[41] [redacted]

01522536



[redacted]

២៦. [redacted]

២៧. សរុបមក តាមពិត យើងមានមូលហេតុសមហេតុផលដែលត្រូវព្រួយបារម្ភនៅពេលនោះ ហើយស្នើសុំមតិយោបល់ជាលាយលក្ខណ៍អក្សរដើម្បីផ្តល់ជូនយើងនូវព័ត៌មានដែលមានកម្រិតចាំបាច់អាចច្បាស់លាស់ និងអាចទុកចិត្តបាន។ ក្នុងករណីណាក៏ដោយ យើងបានរំពឹងទុកថាភាគីពាក់ព័ន្ធ នឹងធ្វើការវាយតម្លៃមកលើយើងជាពិសេស និងប្រកបដោយបទពិសោធន៍វិជ្ជាជីវៈគ្រប់គ្រាន់ ដោយមិនចោទថា យើងបានធ្វើសេចក្តីសន្និដ្ឋានយ៉ាងប្រញាប់ប្រញាល់លើបញ្ហាសំខាន់បែបនេះឡើយ។

**ច. ស្ថានភាពថវិកាតែងតែលំបាក រដ្ឋនានា មិនបំពេញតាមកាតព្វកិច្ចចំណែកថវិការបស់ខ្លួននៅតុលាការអន្តរជាតិផ្សេងទៀត មិនថាតែតាមគំរូថវិកាស្ម័គ្រចិត្ត ឬគំរូថវិកាត្រូវបង់ទេ**

២៨. នេះគឺជាការលើកឡើងគួរឲ្យចាប់អារម្មណ៍។ បើនិយាយអំពីបរិបទនៅក្នុងប្រទេសណាមួយ

វិញ នេះមានន័យថា នៅពេលដែលការពារខ្លួនចំពោះការបង់ពន្ធយឺត មិនបានបង់ពន្ធឲ្យគ្រប់ ឬក៏មិនបានបង់ពន្ធទាល់តែសោះនោះ អ្នកបង់ពន្ធជាទូទៅ លើកឡើងថា អ្នកបង់ពន្ធផ្សេងទៀតនៅក្នុងប្រទេសគាត់ ឬនៅប្រទេសផ្សេងទៀត មិនបានបង់ពន្ធឲ្យទាន់ផង មិនបានបង់ពន្ធឲ្យគ្រប់ ឬក៏មិនបង់ពន្ធទាល់តែសោះ ហើយអាជ្ញាធររដ្ឋដែលពឹងផ្អែកលើការបង់ពន្ធ គួរសម្រួលប្រតិបត្តិការងាររបស់ខ្លួនតាមហ្នឹងទៅ។ យើងមានការលំបាកនឹងយល់អំពីគុណតម្លៃទូទៅនៃទឡ្ហីករណ៍នេះ៖ ប្រទេសផ្តល់ជំនួយដែលបានអនុម័តថវិកា និង ស.ព.អ[42] លើកឡើងថា ខណៈដែលការផ្តល់ថវិកាដោយស្ម័គ្រចិត្តមិនមែនជាគំរូល្អបំផុតនោះ[43] សូម្បីតែបទពិសោធន៍តាមរយៈគំរូថវិកាត្រូវបង់ ក៏បង្ហាញឲ្យឃើញថា រដ្ឋមួយចំនួនមិនបានបង់ចំណែកថវិការបស់ខ្លួនឲ្យទាន់ពេលដែរ ឬក៏មិនបានបង់ឲ្យគ្រប់ ឬក៏មិនបង់ទាល់តែសោះ។ តាមពិតប្រទេសម្ចាស់ជំនួយ និង ស.ព.អ កំពុងតែលើកឡើងថា នេះគ្រាន់តែជារបៀបធ្វើការនៅថ្នាក់អន្តរជាតិតែប៉ុណ្ណោះ ហើយតុលាការនេះត្រូវតែរស់តាមរបៀបហ្នឹង។ ប្រសិនបើនេះគឺជាការរៀបរាប់យ៉ាងត្រឹមត្រូវអំពីសភាពជាក់ស្តែង នោះវាជាការទទួលស្គាល់របស់រដ្ឋនានាអំពីការខកខានមិនបានបំពេញតាមអ្វីដែលគេរំពឹងថាទទួលបានពីរដ្ឋទាំងនោះ តាមសន្ធិសញ្ញា ឬតាមសេចក្តីសម្រេចដែលខ្លួនឯងជាអ្នកបង្កើត ដែលនេះមិនមែនជាយុត្តិកម្មមិនត្រូវបង់ថវិកាតាមចំនួនថវិកាពេញលេញដែលរដ្ឋទាំងនោះបានអនុម័តឡើយ[44]។

## គ. មិនមានលក្ខខណ្ឌតម្រូវផ្នែកច្បាប់ត្រូវ"ធានា"ថវិកាសម្រាប់អំឡុងពេលអាយុកាលរបស់តុលាការទេ

[42] [redacted]

[43] [redacted]

[44] នៅក្នុងបរិបទរបស់ អ.វ.ត.ក មិនមានផងសូម្បីតែការគំរាមកំហែងបាត់បង់សិទ្ធិបោះឆ្នោតដូចនៅសភាភាគីរដ្ឋ របស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ប៉ុន្តែ ក្នុងករណីណាក៏ដោយ ក៏យើងនឹងមិនចាប់អារម្មណ៍ខ្លាំងពេកទេ តាមរយៈឥទ្ធិពលនៃការគំរាមកំហែងបាត់បង់សិទ្ធិបោះឆ្នោតនៅក្នុងអង្គភាពមួយដែលគេមិនមានឆន្ទៈផ្តល់ការគាំទ្រផ្នែកហិរញ្ញវត្ថុតាំងពីដំបូង ហើយជាអង្គភាពមួយដែលគ្មានអំណាចចាត់វិធានការឲ្យអនុវត្តនោះ។

01522538



២៩. យើងសង្កេតឃើញថា ប្រទេសម្ចាស់ជំនួយ ហាក់ដូចជាសង្កត់ធ្ងន់ជាពិសេសលើពាក្យ "ធានា "។ នេះបង្ហាញឱ្យឃើញថាមិនច្បាស់។ យើងគ្រាន់តែប្រើប្រាស់ពាក្យ "ធានា"នៅក្នុងអត្ថន័យហិរញ្ញវត្ថុ សម្រាប់បរិបទពាក់ព័ន្ធនឹងករណីនេះនៅផ្នែកនានានៃសំណើដូចខាងក្រោម៖

ក. "តាមខ្លឹមសារសាមញ្ញត្រង់នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ភាពខុសគ្នារវាងចំណាយទាំងពីរប្រភេទនេះ បង្ហាញឱ្យឃើញថា មួយជាប្រភេទចំណាយដែលត្រូវធានាដោយ អ.ស.ប ហើយមួយទៀតពឹងផ្អែកលើជំនួយបន្ថែមដែលមិនមានការធានា"[45]។

ខ. "វានឹង[...]ក្លាយជាអំពើមិនទទួលខុសត្រូវផ្នែកសីលធម៌ ប្រសិនបើសហគមន៍អន្តរជាតិបង្កើតប្រព័ន្ធតុលាការព្រហ្មទណ្ឌ ជាពិសេសពាក់ព័ន្ធនឹងការបាត់បង់សេរីភាពដោយសារការចាប់ខ្លួន និងការឃុំខ្លួន ហើយអាចឈានដល់កាត់ទោសឱ្យជាប់ឃុំខ្លួនផងដែរ ដោយសារប្រព័ន្ធតុលាការនេះខ្វះការធានាថវិកា ដែលចាំបាច់ដើម្បីបញ្ចប់ភារកិច្ចរបស់ខ្លួន"[46]។

៣០. អត្ថន័យនៃការប្រើប្រាស់ពាក្យ"ធានា"របស់យើងនៅចំណុច ក គឺមានលក្ខណៈច្បាស់តាមបរិបទ។ ការប្រើប្រាស់ពាក្យ "ធានា"នៅចំណុច ខ សំដៅលើបញ្ហាចោទអំពីគោលការណ៍ទូទៅពីបរិបទតុលាការមួយផ្សេងទៀត។ អ្វីដែលចង់មានន័យគឺថា កិច្ចព្រមព្រៀងរវាង អ.ស.ប ជាមួយរាជរដ្ឋាភិបាលកម្ពុជា តម្រូវឱ្យ អ.ស.ប និងរាជរដ្ឋាភិបាលកម្ពុជា("ត្រូវទទួលខុសត្រូវ")ជាប់កាតព្វកិច្ចត្រូវបង់ចំណាយចំណែកមួយចំនួន ដរាបណាកិច្ចព្រមព្រៀងនៅជាធរមាន ហើយតុលាការនៅមានសកម្មភាព។ នេះហើយជាបញ្ហាគន្លឹះពិតប្រាកដ។

៣១. ករណីកិច្ចព្រមព្រៀងនៅជាធរមាន ឬករណីកិច្ចព្រមព្រៀងមិននៅជាធរមាន។ ក្នុងករណីកិច្ចព្រមព្រៀងនៅជាធរមាន ភាគីកិច្ចព្រមព្រៀងជាប់កាតព្វកិច្ចត្រូវចូលរួមចំណែកថវិការបស់ខ្លួន ។ ត្រង់នេះមិនពាក់ព័ន្ធថាតើការចូលរួមចំណែកនេះធ្វើឡើងដោយថវិកាស្ម័គ្រចិត្ត ឬក៏មិនធ្វើឡើងដោយថវិកាស្ម័គ្រចិត្តតាមរយៈអ្វីដែលបង្ហាញឱ្យឃើញថាជាថវិកាទទួលបានពីភាគីទីបីនោះទេ។ ប៉ុន្តែ និយាយឱ្យដាច់ខាតទៅ មិនមានភាគីទីបីទេ ពីព្រោះថា រដ្ឋនានាដែលបានបដិសេធគំរូថវិកាត្រូវបង់ ហើយក្នុងករណីរបស់យើង ក៏ជារដ្ឋដែលបានបដិសេធចំនួនថវិកា

---

45 [redacted]

46 សំណើ កថាខណ្ឌ ៦៩ ដកស្រង់ពីមតិយោបល់ដាច់ដោយឡែករបស់ចៅក្រម Geoffrey Robertson។

ឧបត្ថម្ភធននាពេលថ្មីៗនេះដែលបានស្នើឡើងដែរ ពោលគឺជារដ្ឋដែលដែលត្រូវតែបំពេញថវិកាខ្វះខាត ដោយបង់ថវិកាស្ម័គ្រចិត្ត។ "ចំណែកថវិកាស្ម័គ្រចិត្ត"ក្នុងករណីនេះមានន័យផ្ទុយពី"ចំណែកថវិកាត្រូវបង់" គឺថាតំរូវថវិកាស្ម័គ្រចិត្ត ដាក់បន្ទុកលើរដ្ឋសមាជិកខ្លះរបស់ អ.ស.ប ហើយមិនដាក់បន្ទុកលើរដ្ឋសមាជិកទាំងអស់ទេ ចំណែកឯ តំរូវថវិកា ត្រូវបង់វិញ នឹងត្រូវដាក់បន្ទុកលើរដ្ឋសមាជិកទាំងអស់របស់ អ.ស.ប។ នៅក្នុងបរិបទនេះ ពាក្យ "ស្ម័គ្រចិត្ត" មិនអាចមានន័យថាជា"ជម្រើស"ទេ។

៣២. ប្រសិនបើកិច្ចព្រមព្រៀងត្រូវបញ្ចប់វិញ កាតព្វកិច្ចទាំងនេះត្រូវបញ្ចប់ ហើយ តុលាការក្នុងរូបភាពបច្ចុប្បន្ននេះត្រូវរស់ជីវិតដែរ។ ការគ្រាន់តែមិនបានបំពេញតាមកាតព្វកិច្ចទាំងនេះមិនប៉ះពាល់ដល់សុពលភាពនៃកិច្ចព្រមព្រៀងទេ ប្រសិនបើមិនចាប់ផ្តើមអនុវត្តយន្តការច្រកចេញបញ្ចប់ការងារ តាមកិច្ចព្រមព្រៀងទេ។ អ្វីដែលយើងបានសំដៅលើនោះគឺគ្រាន់តែថា ភាគីកិច្ចព្រមព្រៀងគួរគោរពតាមកិច្ចសន្យាដែលខ្លួនឯងត្រូវធ្វើ។ ។

**ជ. ក្របខណ្ឌថវិការបស់ អ.ស.ប និងរដ្ឋសមាជិកនៃក្រុមប្រទេសផ្តល់ជំនួយសំខាន់ៗ មិនអនុញ្ញាតឱ្យមាន "ការធានា"ផ្តល់ថវិកាជាមុនសម្រាប់អាយុកាលរបស់តុលាការទេ**

៣៣. ទឡ្ហីករណ៍នេះទាក់ទងនឹងទឡ្ហីករណ៍មុននេះ ហើយក៏មិនគួរជឿជាក់ប៉ុនគ្នា។ យើងយល់ពីភាពតឹងតែងដែលកើតឡើងដោយសារនីតិវិធីថវិកាផ្ទៃក្នុងរបស់ប្រទេសម្ចាស់ជំនួយ ប៉ុន្តែ ចុងក្រោយបំផុត មិនអាចឲ្យភាពតឹងតែងនេះជាអ្នកសម្រេចលើបញ្ហាបច្ចុប្បន្ននេះទេ។ ភាគីកិច្ចព្រមព្រៀង អាចផ្តល់ទឡ្ហីករណ៍ឱ្យមានការជំនួសការបង់ថវិការបស់ខ្លួនតាមរយៈថវិកាស្ម័គ្រចិត្តពីអ្នកផ្សេង ប្រសិនបើមានការឯកភាពតាមការបកស្រាយកិច្ចព្រមព្រៀងក្នុងរបៀបនេះដូចដែលយើងបានវិភាគនៅក្នុងសំណើ[47]។ ប៉ុន្តែ នៅក្នុងកិច្ចព្រមព្រៀង មានការលើកឡើងដោយប្រយោលថា របៀបបង់ថវិកា ត្រូវតែអាចឱ្យតុលាការដំណើរការទៅឱ្យបានត្រឹមត្រូវ៖ កិច្ចព្រមព្រៀងធ្វើឡើងជាមធ្យោបាយមួយដើម្បីសម្រេចគោលដៅផ្សេង មិនមែនសម្រេចគោលដៅខ្លួនឯងទេ។ គោលដៅមួយ និងតែមួយគត់នៃកិច្ចព្រមព្រៀង គឺដើម្បីបង្កើតអាណត្តិរបស់តុលាការ បន្ទាប់មក បម្រើតាមអាណត្តិរបស់តុលាការ។ នេះក៏មានន័យថា ភាគីកិច្ចព្រមព្រៀង មិនអាចលើកឡើងពីនីតិវិធីផ្ទៃក្នុងបានឡើយប្រសិនបើការធ្វើរបៀបនេះរំលោភលើ

47 [redacted]

គោលបំណងនៃកិច្ចព្រមព្រៀង។ ភាគីកិច្ចព្រមព្រៀង ត្រូវតែធ្វើការកែសម្រួលឱ្យសមហេតុផលសម្រាប់សេណារីយ៉ូខុសប្លែកនេះ ដែលក្នុងករណីណាក៏ដោយ នេះមិនមែនជាអ្វីដែលមិនអាចគិតទុកមុនបានទេនៅពេលដែលចុះហត្ថលេខាលើកិច្ចព្រមព្រៀងនោះ។

៣៤. តាមពិត រូបភាពនៃដំណោះស្រាយបែបនេះគឺជាបញ្ហាសុទ្ធសាធរបស់ អ.ស.ប និងរដ្ឋនានា ប៉ុន្តែ ដំណោះស្រាយត្រូវតែស្វែងរកដែលអាចឱ្យស្ថាប័នតុលាការមួយដំណើរការទៅយ៉ាងរលូនក្នុងគោលបំណងធានាឱ្យមានការស៊ើបសួរ ហើយក្នុងករណីបញ្ជូនទៅជំនុំជម្រះ ត្រូវធានាឱ្យមានការជំនុំជម្រះក្តីយ៉ាងឆាប់រហ័ស ដោយគោរពសិទ្ធិការពារក្តី។

## ឈ. ការប្រើប្រាស់ការកំណត់ថវិកាផ្អែកតាមលទ្ធផល

៣៥. នៅក្នុងសំណើ យើងបានពន្យល់ថា ការប្រើប្រាស់ការកំណត់ថវិកាផ្អែកតាមលទ្ធផល "សមិទ្ធផលសំខាន់ៗ"ជារង្វាស់វាស់វែងភាពជោគជ័យ និង/ឬវឌ្ឍនភាពនៅក្នុងដំណើរការធ្វើសេចក្តីសម្រេចរបស់តុលាការ គឺមិនស្របតាមឯករាជ្យភាពតុលាការក្នុងការធ្វើសេចក្តីសម្រេចទេ[48]។ យើងយោងលើសេចក្តីពន្យល់ទាំងនោះ ហើយសូមអនុញ្ញាតផ្តល់សេចក្តីអង្កេតដូចខាងក្រោម។

៣៦. សារណារបស់ការិយាល័យរដ្ឋបាល និងការបញ្ជាក់របស់ អ.ស.ប ក៏មិនស្របគ្នាទាំងស្រុងដែរ។ អ.ស.ប ផ្តល់ទឡ្ហីករណ៍[49]ថា តាមសេចក្តីសម្រេចលេខ ST/SGB2016/6 *"ដែលចង្អុលបង្ហាញថា 'នៅក្នុងសំណើថវិកាកម្មវិធី ធនធានដែលបានស្នើ ត្រូវបង្ហាញយុត្តិកម្មគិតពីលទ្ធផលការងារជាការចូលរួមចំណែកដល់សមិទ្ធផលដែលបានរំពឹងទុក' សំណើនាពេលអនាគតសុំថវិកាឧបត្ថម្ភធនសម្រាប់ អ.វ.ត.ក ពីថវិកាកម្មវិធី ត្រូវតែដាក់ និងបង្ហាញជូនក្នុងទម្រង់ផ្អែកតាមលទ្ធផល"*។ ពិបាកសម្រួលពាក្យពេចន៍ទាំងនេះឱ្យត្រូវតាមភាសាដែលការិយាល័យរដ្ឋបាលបានប្រើប្រាស់នៅក្នុងសារណារបស់ខ្លួន ដែលបញ្ជាក់ថា *"ការផ្តល់ថវិកានាពេលអនាគតមិនអាស្រ័យលើភាពជោគជ័យក្នុងការសម្រេចបានសមិទ្ធផលដែលបានរំពឹង ទុកជាមុន*

48 [redacted]

49 [redacted]

01522541



*តាមរង្វាស់សូចនាករណ៍សមិទ្ធផលការងារទេ*[50]។ សារណារបស់ការិយាល័យរដ្ឋបាល ពិតជាលើកឡើងពីបញ្ហាចោទថាតើការកំណត់ថវិកាផ្អែកតាមលទ្ធផល អាចមានប្រយោជន៍អ្វី ប្រសិនបើមិនតម្រូវឱ្យមានភាពជោគជ័យតាមសូចនាករណ៍សមទ្ធិផលមួយចំនួនដើម្បីកំណត់ថវិកានាពេលអនាគតនោះ។

៣៧. នៅក្នុងបរិបទនេះ គួរកត់សម្គាល់ថា នាពេលថ្មីៗនេះ តុលាការព្រហ្មទណ្ឌអន្តរជាតិ បានខិតខំប្រឹងប្រែងបង្កើតសូចនាករណ៍លទ្ធផលការងារផ្ទាល់ខ្លួន ដែលនេះគឺជាឧទាហរណ៍មួយជាក់ស្តែងអំពីការលំបាកដែលតុលាការមួយប្រឈមមុខ នៅពេលដែលព្យាយាមសម្របសម្រួលរវាងតម្រូវការផ្នែកគ្រប់គ្រងនិយមរបស់សហគមន៍ប្រទេសផ្តល់ជំនួយអំពីប្រសិទ្ធភាព និងប្រសិទ្ធផលការងារ ជាមួយនឹងតម្រូវការនៅក្នុងគោលការណ៍ការជំនុំជម្រះក្តីដោយយុត្តិធម៌។ តុលាការព្រហ្មទណ្ឌអន្តរជាតិ បានចេញរបាយការណ៍មួយស្តីពីការបង្កើតសូចនាករណ៍លទ្ធផលការងារ ចុះថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ២០១៦ (“របាយការណ៍”)[51] ជាការឆ្លើយតបទៅនឹងសំណើដែលសភាភាគីរដ្ឋបានធ្វើឡើងនៅឆ្នាំ ២០១៤ សុំឱ្យតុលាការព្រហ្មទណ្ឌអន្តរជាតិបង្កើតសូចនាករណ៍គុណភាព និងគុណបរិមាណ ដើម្បីបង្ហាញពីសមិទ្ធផល និងតម្រូវការរបស់តុលាការ និងដើម្បីឱ្យភាគីរដ្ឋនានាអាចវាយតម្លៃកាន់តែមានលក្ខណៈជាយុទ្ធសាស្ត្រលើការអនុវត្តការងាររបស់តុលាការ[52]។

៣៨. នៅក្នុងរបាយការណ៍ មានការបង្ហាញសូចនាករណ៍ចំនួន ៤ ដូចខាងក្រោម៖

ក. កិច្ចដំណើរការនីតិវិធីរបស់តុលាការ ត្រូវឆាប់រហ័ស យុត្តិធម៌ និងតម្លាភាព នៅគ្រប់ដំណាក់កាលទាំងអស់។

---

[50] [redacted]

[51] តុលាការព្រហ្មទណ្ឌអន្តរជាតិ “របាយការណ៍តុលាការលើកទី ២ ស្តីពីការបង្កើតសូចនាករណ៍លទ្ធផលការងារសម្រាប់តុលាការព្រហ្មទណ្ឌអន្តរជាតិ” ថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ២០១៦។

[52] ដូចជើងទំព័រខាងលើ កថាខណ្ឌ ១។

ខ. ការដឹកនាំ និងការគ្រប់គ្រងរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ត្រូវមានប្រសិទ្ធភាព។

គ. តុលាការព្រហ្មទណ្ឌអន្តរជាតិ ធានាឱ្យមានសន្តិសុខគ្រប់គ្រាន់សម្រាប់ការងាររបស់ខ្លួន ដូចជា ការពារជនដែលស្ថិតនៅក្នុងស្ថានភាពហានិភ័យដោយសារចូលរួមជាមួយតុលាការ។

ឃ. ជនរងគ្រោះមានលទ្ធភាព(គ្រប់គ្រាន់)នៅក្នុងតុលាការ។[53]

៣៩. មានការបង្ហាញឱ្យឃើញថា ជាគោលការណ៍ សូចនាករណ៍ចំនួន ៣ ក្នុងចំណោមសូចនាករណ៍ទាំង ៤ នេះ គឺពាក់ព័ន្ធនឹងការគ្រប់គ្រង ឬសេវាជំនួយ។ កន្លងមកនេះ ការពិភាក្សាអំពីអន្តរតួនាទីនៃសូចនាករណ៍ទាំងនេះបានបង្ហាញឱ្យឃើញពី៖

> [...] បញ្ហាចោទអំពីលទ្ធភាពជោគជ័យនៃការប្រើប្រាស់សូចនាករណ៍លទ្ធផលការងារសម្រាប់តុលាការអន្តរជាតិ និងតម្រូវការរក្សាឯករាជ្យភាពតុលាការ និងអយ្យការខណៈដែលព្យាយាមឱ្យមានការអនុវត្តការងារយ៉ាងល្អនៅក្នុងស្ថាប័ន។ មានការសង្កត់ធ្ងន់ផងដែរថា ក្នុងផ្នែកជាច្រើនការអនុវត្តការងាររបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ គឺពឹងផ្អែកលើការគាំទ្រ និងកិច្ចសហការដែលខ្លួនទទួលបានពីសហគមន៍អន្តរជាតិ[54]។

៤០. របាយការណ៍ ទទួលស្គាល់យ៉ាងច្បាស់អំពីភាពស្មុគស្មាញនៃការជ្រើសរើសសូចនាករណ៍ជាពិសេសពាក់ព័ន្ធនឹងភាពយុត្តិធម៌នៃកិច្ចដំណើរការនីតិវិធី ដែលអាចមានការលំបាកខ្លាំងក្នុងការវាស់វែង។ របាយការណ៍ កត់សម្គាល់ថា គោលដៅនៃភាពយុត្តិធម៌ អាចប្រឆាំងជាមួយនឹងគោលដៅនៃភាពឆាប់រហ័សនៃកិច្ចដំណើរការនីតិវិធី ដែលនេះគឺជាភស្តុតាងបញ្ជាក់ពីភាពលំបាកក្នុងការវាស់វែងគុណភាពលើការអនុវត្តការងាររបស់ស្ថាប័នតុលាការ។

៤១. របាយការណ៍ ទទួលស្គាល់ប្រកបដោយគតិបណ្ឌិតថា ល្បឿននៃកិច្ចដំណើរការនីតិវិធីនឹងត្រូវបង្អាក់ដោយសារពេលវេលា និងការចូលរួមដែលត្រូវតែផ្តល់ជូនទៅភាគីទាំងអស់ ឱ្យស្រប

[53] ដូចដើងទំព័រខាងលើ កថាខណ្ឌ ៥ ។ ចុងក្រោយបំផុត ពាក្យ "គ្រប់គ្រាន់"ត្រូវដកចេញពីរបាយការណ៍ ខុសពីរបាយការណ៍មុន។

[54] ដូចជើងទំព័រខាងលើ កថាខណ្ឌ ១៤។

តាមតម្រូវការដែលត្រូវមានយុត្តិធម៌ផ្នែកកិច្ចដំណើរការនីតិវិធី និងត្រូវបញ្ជាក់ពីការពិត[55] ហើយនៅក្នុង

> [...] ការអនុវត្តជាក់ស្តែង អ្វីដែលបង្ហាញឲ្យឃើញថាត្រូវប្រើប្រាស់ច្រើនបំផុតដើម្បីវាស់វែងភាពយុត្តិធម៌នៅថ្នាក់ជាតិគឺ ស្ថានការណ៍ទំហំការងារលើបញ្ហាការពារក្តីដែលអាចចង្អុលបង្ហាញពីកម្រិតភាពយុត្តិធម៌នៃកិច្ចដំណើរការនីតិវិធី(ដូចជា ពេលវេលាដែលត្រូវចំណាយដើម្បីដោះស្រាយសេចក្តីព្រួយបារម្ភរបស់ភាគីការពារក្តី ពេលវេលាដែលត្រូវផ្តល់ជូនទៅភាគីការពារក្តីដើម្បីរៀបចំសំណុំរឿងរបស់ខ្លួន ។ល។)[56]

៤២. របាយការណ៍ បានព្រមានជាមុនថា រយៈពេល និងល្បឿននៃកិច្ចដំណើរការនីតិវិធី មិនអាចប្រៀបស្មើជាមួយនឹងប្រសិទ្ធផលការងារបានទេ ដោយកត់សម្គាល់ថា ត្រូវតែយកចិត្តទុកដាក់ដើម្បីថ្លឹងថ្លែងឲ្យស្មើគ្នារវាងល្បឿន ជាមួយនឹងភាពយុត្តិធម៌។ របាយការណ៍ ក៏បានព្រមានជាមុនថាមិនមានបទដ្ឋានដូចគ្នាគ្រប់សំណុំរឿងឡើយ ដោយបញ្ជាក់ថា

> "សំណុំរឿងនីមួយៗមានលក្ខណៈពិសេសរៀងខ្លួន ហេតុនេះ ដាច់ខាត មិនអាចមានបទដ្ឋានពីសំណុំរឿងមួយទៅសំណុំរឿងមួយទៀតទេ។ រយៈពេលនៃសំណុំរឿងនីមួយៗគឺអាស្រ័យលើកត្តារឿងក្តីជាក់លាក់មួយចំនួន ដូចជា ចំនួនជនជាប់ចោទ ចំនួនបទចោទ លក្ខណៈបទចោទ ចំនួនភស្តុតាង ចំនួនសាក្សីសក្តានុពល និងវិសាលភាពភូមិសាស្ត្រនៃសំណុំរឿង (ទីតាំងភូមិសាស្ត្រក្នុងស្រុក ឬជាទូទៅ) កិច្ចសហការពីរដ្ឋនានាក្នុងការផ្តល់ជំនួយដែលត្រូវការជាចាំបាច់ និងល្បឿននៃការផ្តល់ជំនួយបែបនេះ។ កត្តាទាំងនេះ ឬរួមជាមួយនឹងកត្តាពាក់ព័ន្ធផ្សេងទៀត អាចចូលរួមចំណែកក្នុងការវាយតម្លៃអំពីភាពស្មុគស្មាញនៃរឿងក្តីណាមួយ ដែលទំនងជាប៉ះពាល់ដល់រយៈពេលជាទូទៅនៃរឿងក្តីនោះ។ ជាគោលការណ៍ រឿងក្តីណាមួយកាន់តែស្មុគស្មាញ និងមានទំហំកាន់តែធំ គឺរឿងក្តីនោះកាន់តែមានរយៈពេលយូរ[57]។

៤៣. ដូចគ្នានេះដែរ ជាគោលការណ៍ ការពិចារណាទាំងនេះក៏អនុវត្តផងដែរមកលើកិច្ចដំណើរការនីតិវិធីនៅចំពោះមុខ អ.វ.ត.ក។ ការរកឃើញនានានៅក្នុងរបាយការណ៍ គាំទ្រយើងជួយពង្រឹងការយល់ឃើញរបស់យើងដែលថា ទោះបីជាមាននិន្នាការជំរុញដោយផ្នែកនីតិប្រតិបត្តិ

[55] ដូចជើងទំព័រខាងលើ កថាខណ្ឌ ២៩។

[56] ដូចជើងទំព័រខាងលើ កថាខណ្ឌ ៣២។

[57] ដូចជើងទំព័រខាងលើ កថាខណ្ឌ ៣៥-៣៦។

ក៏ដោយ ក៏ការអនុវត្តលក្ខខណ្ឌផ្នែកគ្រប់គ្រងមកលើសកម្មភាពស្នូលរបស់តុលាការ[58] ប្រាកដជាត្រូវបញ្ចប់ទស្សនៈឯករាជ្យរបស់តុលាការ ជាការឥតប្រយោជន៍ ឬក៏មានហានិភ័យអាចប៉ះពាល់គ្រោះថ្នាក់ដល់ទស្សនៈឯករាជ្យរបស់តុលាការ[59]។

## ញ. គ្មានឥទ្ធិពលពីក្រុមប្រទេសផ្តល់ជំនួយសំខាន់ៗមកលើការស៊ើបសួររបស់តុលាការទេ

៤៤. យើងកត់សម្គាល់លើការបង្ហាញសេចក្តីសោកស្តាយពីក្រុមប្រទេសផ្តល់ជំនួយសំខាន់ៗចំពោះការលើកឡើងដែលថា ក្រុមប្រទេសផ្តល់ជំនួយសំខាន់ៗអាចព្យាយាមធ្វើឱ្យមានឥទ្ធិពលមក

---

[58] *សូមមើលឧទាហរណ៍* អំពីអង្គសេចក្តីជាក់ស្តែងនៃសេចក្តីសម្រេចផ្នែកគ្រប់គ្រងនៅក្នុងការអនុវត្តជាក់ស្តែង Maximo Langer "ការកើនឡើងនូវសេចក្តីសម្រេចផ្នែកគ្រប់គ្រងនៅក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ" ឆ្នាំ ២00៥ ទិន្នានុប្បវត្តិ *American Journal of Comparative Law* ឆ្នាំទី ៥៣ ទំព័រ ៨៣៥-៩0៩ (ភាសាអង់គ្លេស)។ Maximo Langer & Joseph W. Doherty "សេចក្តីសម្រេចផ្នែកគ្រប់គ្រងក្លាយទៅជាលក្ខណៈអន្តរជាតិ ប៉ុន្តែ ការសន្យានៅតែមិនទាន់ធ្វើតាម៖ ការវាយតម្លៃការអនុវត្តជាក់ស្តែងលើកំណែទម្រង់តុលាការ ICTY" ឆ្នាំ ២0១១ ទិន្នានុប្បវត្តិ *The Yale Journal of International Law* ឆ្នាំទី ៣៦ ទំព័រ ២៤១-៣0៥(ភាសាអង់គ្លេស)។

[59] សូមមើលជាពិសេស តុលាការព្រហ្មទណ្ឌអន្តរជាតិ គោលការណ៍ផ្ទាល់ខ្លួនរបស់ការិយាល័យអយ្យការស្តីពីសូចនាករណ៍លទ្ធផលការងារ Birju Kotecha "តុលាការព្រហ្មទណ្ឌអន្តរជាតិ ការិយាល័យអយ្យការ និងដែនកំណត់នៃសូចនាករណ៍លទ្ធផលការងារ" ឆ្នាំ ២0១៧ ទិន្នានុប្បវត្តិ *Journal of International Criminal Justice* (advance article doi:10.1093/jicj/mqx028)។ Kotecha បញ្ជាក់យ៉ាងត្រឹមត្រូវថា *"ទីមួយ ការសង្កត់សំខែ មានហានិភ័យអាចធ្វើឱ្យគោលបំណងនៃវង្វាស់លទ្ធផលការងារក្លាយទៅជាឧបករណ៍និរាមញក្នុងការផ្តល់រង្វាន់ ឬក៏ដាក់ទណ្ឌកម្ម។ នេះក៏មានជំនឿថា តួលេខតឹងរឹងគឺជាមូលដ្ឋានដើម្បីឱ្យមានការវិនិច្ឆ័យដ៏រឹងមាំពីភាគីខាងក្រៅ និងដើម្បីស្វែងរកថវិកា។ ទីពីរ ហើយក៏មានការពាក់ព័ន្ធគ្នាដែរគឺថា ការសង្កត់សំខែជំរុញឱ្យសូចនាករណ៍លទ្ធផលការងារ បង្កើតចិន្តន័យរឹងមាំឱ្យបានច្រើនតាមដែលអាចធ្វើទៅបានសម្រាប់ធ្វើសវនកម្ម។ ដូចបានលើកឡើងជាទត្ថិករណ៍នៅក្នុងឯកសារជំទាញដែរ ការធ្វើសវនកម្ម និងការបង្កើតសូចនាករណ៍លទ្ធផលការងារ គឺមានសារៈសំខាន់ទៅវិញទៅមក។ ការបង្កើតវង្វាស់លទ្ធផលការងារ មានទិន្នាការឱ្យស្របតាមរូបភាព និងការអនុវត្តនៃការធ្វើសវនកម្ម។ ហេតុនេះ ទាំងគណនីយភាព ទាំងសវនកម្ម ពន្យល់ពីមូលហេតុដែលការិយាល័យអយ្យការផ្តល់អាទិភាពលើសូចនាករណ៍ ដោយផ្អែកលើលទ្ធផលការងាររបស់អយ្យការ គឺដោយសារថា សូចនាករណ៍អាចកែតម្រូវបានឱ្យត្រូវតាមបទដ្ឋានលទ្ធផលការងារដែលអាចធ្វើសវនកម្មបាន។ បន្ទាប់មកគេគួរចោទសួរថាតើហេតុអ្វីដែលបានជាវង្វាស់លទ្ធផលការងារដែលមានកំណើតពីសវនកម្មនោះ មិនបានបញ្ចូល ឬក៏មិនបានជំរុញឱ្យមានវង្វាស់ប្រសិទ្ធភាពការងាររបស់អយ្យការទេ។ ជាទូទៅ មានការពន្យល់មួយថា សូចនាករណ៍ទាំងនេះអាចបង្កើតឱ្យមានវប្បធម៌ខ្លាំងក្លា(ហើយមិនបានរំពឹងទុកជាមុន)សម្រាប់បុគ្គលិកនៅក្នុងអង្គភាព។ សរុបមក សូចនាករណ៍សវនកម្ម អាចបង្កើតគុណតម្លៃសវនកម្មយ៉ាងស៊ីជម្រៅនៅក្នុងអត្តសញ្ញាណវិជ្ជាជីវៈ។ នេះអាចនាំឱ្យបុគ្គលិកផ្លាស់ប្តូរចក្ខុវិស័យរបស់ខ្លួនអំពីខ្លួនឯងជានរណានៅក្នុងវិជ្ជាជីវៈ ហើយអ្វីដែលខ្លួនឯងត្រូវធ្វើ"* ទំព័រ ១៣ (ភាសាអង់គ្លេស)។

លើការស៊ើបសួររបស់តុលាការតាមរយៈការបែងចែកថវិកា។ យើងសូមសម្តែងការសោកស្តាយមិនយល់ស្របតាមការបង្ហាញសេចក្តីសោកស្តាយហួសហេតុបែបនេះទេ។ ចំពោះរឿងជាច្រើនណាស់ បញ្ហាថាតើមានការយល់ឃើញថាមានឥទ្ធិពលឬអត់នោះគឺស្ថិតនៅលើការវាយតម្លៃអត្តនោម័តទេ។

៤៥. មេធាវីការពារក្តី មាស មុត បានចង្អុលបង្ហាញយ៉ាងត្រឹមត្រូវ[60]អំពីការវិវត្តនៃការស្នើថវិកាសម្រាប់ឆ្នាំ ២០១៧ នៅសហរដ្ឋអាមេរិក ជាប្រទេសមួយក្នុងចំណោមប្រទេសផ្តល់ជំនួយសំខាន់ៗនៅក្នុងក្រុមប្រទេសផ្តល់ជំនួយសំខាន់ៗ។ ការស្នើច្បាប់ថវិកានេះ និងសេចក្តីរាយការណ៍អមជាមួយ មានផ្នែកនានាដូចខាងក្រោម៖

ក. "(២)សាលាក្តីខ្មែរក្រហម៖ ថវិកាដែលត្រូវចំណាយតាមច្បាប់នេះអាចផ្តល់ឱ្យដើម្បីជួយប្រទេសកម្ពុជា អាចផ្តល់ឱ្យបានជាការចូលរួមចំណែកថវិកាដល់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) **ប្រសិនបើរដ្ឋមន្ត្រីការបរទេស បញ្ជាក់ និងរាយការណ៍ជូនគណៈកម្មាធិការទទួលបន្ទុកលើការផ្តល់ថវិកា ថា អ.វ.ត.ក នឹងពិចារណាសំណុំរឿង 00៣**៖ ដរាបណា ថវិកាបែបនេះត្រូវមានការពិគ្រោះយោបល់ជាមុនជាមួយគណៈកម្មាធិការបែបនេះ ហើយត្រូវអនុវត្តតាមនីតិវិធីជូនដំណឹងជាទៀងទាត់របស់គណៈកម្មាធិការបែបនេះ៖ ដរាបណា រដ្ឋមន្ត្រីការបរទេស ត្រូវស្វែងរកការបង់ថវិកាឱ្យវិញពីក្រុមប្រទេសផ្តល់ជំនួយសំខាន់ៗ ឱ្យទៅមជ្ឈមណ្ឌលឯកសារកម្ពុជា ចំពោះចំណាយដែលបានកើតឡើងដើម្បីគាំទ្រ អ.វ.ត.ក"[61]។

ខ. "បន្ថែមពីលើនេះទៀត ផ្នែក៧០៤៣(គ)(២) នៃច្បាប់នេះ កំណត់ការចូលរួមចំ**ណែកថវិការបស់សហរដ្ឋអាមេរិក សម្រាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា [អ.វ.ត.ក] តែនៅត្រឹមសំណុំរឿង 00៣ ទាក់ទងនឹង មាស មុត អតីតមេបញ្ជាការកងទ័ពជើងទឹកខ្មែរក្រហម ដែលជាប់ពាក់ព័ន្ធនៅក្នុងហេតុការណ៍កប៉ាល់**

---

[60] [redacted]

[61] សភាសហរដ្ឋអាមេរិក S.3117 (របាយការណ៍លេខ 114-290) *ការស្នើច្បាប់ផ្តល់ថវិកាសម្រាប់ក្រសួងការបរទេស ប្រតិបត្តិការបរទេស និងកម្មវិធីពាក់ព័ន្ធ សម្រាប់ឆ្នាំសារពើពន្ធបញ្ចប់នៅថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០១៧ និងសម្រាប់គោលបំណងផ្សេងទៀត* ថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០១៦ នៅគេហទំព័រ៖ www.appropriations/senate/gov/imo/media/doc/FY2017-State-Foreign-Operations- Appropriations-Report 114 290.pdf ទំព័រ ២២១។

**ម៉ាយ៉ាហ្គេសឆ្នាំ ១៩៧៥។ គណៈកម្មាធិការអនុម័តផែនការរបស់ក្រសួងការបរទេស ដើម្បីបញ្ឈប់ការចូលរួមចំណែកថវិកាសម្រាប់ អ.វ.ត.ក ប្រសិនបើសំណុំរឿង ០០៣ ចេញដីកាដំណោះស្រាយ"[62]។**

៤៦. ក្រៅពីអង្គហេតុដែលថា ក្រុមប្រទេសផ្តល់ជំនួយសំខាន់ៗ ក៏បង្ហាញឱ្យឃើញថាមានបំណងចំណាយថវិកាសម្រាប់ការងាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ក្នុងការគាំទ្រ អ.វ.ត.ក[63] ដោយការចំណាយថវិកាបែបនេះអាចកាត់បន្ថយថវិកាជាទូទៅដែលអាចមានសម្រាប់ អ.វ.ត.ក នោះ ការស្នើច្បាប់ថវិកា និងសេចក្តីរាយការណ៍ខាងលើ តាមការបកស្រាយសមហេតុផលតែមួយគត់ គឺរំពឹងទុកថា សហរដ្ឋអាមេរិក គួរ ក) កម្រិតការចូលរួមចំណែកថវិការបស់ខ្លួននៅត្រឹមសំណុំរឿង ០០៣ និង ខ) បញ្ឈប់ការចូលរួមចំណែកថវិកាទាំងអស់ដល់ អ.វ.ត.ក ប្រសិនបើយើងលើកលែងការចោទប្រកាន់នៅក្នុងសំណុំរឿង ០០៣[64]។ ការស្នើច្បាប់ថវិកា និងសេចក្តីរាយការណ៍នេះ ក៏ហាក់ដូចជាផ្តោតលើហេតុការណ៍កប៉ាល់ម៉ាយ៉ាហ្គេស ដែលប៉ះពាល់ដល់ពលរដ្ឋអាមេរិក ដោយយកជាមូលហេតុសមស្របដើម្បីផ្តល់ថវិកាសម្រាប់សំណុំរឿង ០០៣។

---

[62] សភាសហរដ្ឋអាមេរិក របាយការណ៍អម *S. 3117*, 29 June 2016 នៅគេហទំព័រ www.congress.gov/congressional-report/114th-congress/senate-report/290/1 ទំព័រ ១៥។

[63] យើងកត់សម្គាល់ថា តាមការយល់ឃើញរបស់ អ.វ.ត.ក ឯកសារបណ្ណសារទាំងអស់ដែលតម្កល់ទុកនៅមជ្ឈមណ្ឌលឯកសារកម្ពុជា គឺជាភស្តុតាងសក្តានុពល ហើយតាមច្បាប់ មជ្ឈមណ្ឌលឯកសារកម្ពុជា ជាប់កាតព្វកិច្ចត្រូវអនុញ្ញាតឱ្យ អ.វ.ត.ក ចូលពិនិត្យឯកសារទាំងនោះ។ ចុងក្រោយបង្អស់ ឯកសារទាំងនោះអាចត្រូវស្វែងរក និងដកហូតផង។

[64] សហមេធាវីអន្តរជាតិការពារក្តី មាស មុត បានចង្អុលបង្ហាញយ៉ាងត្រឹមត្រូវអំពីកង្វះការយល់ដឹងអំពីការប្រើប្រាស់ពាក្យបច្ចេកទេសនីតិវិធីរបស់ អ.វ.ត.ក ពីសំណាក់អ្នករៀបចំសេចក្តីព្រាងការស្នើច្បាប់ថវិកាផ្នែកនេះ សូមមើល៖ *ជំរុញឱ្យមានលទ្ធផលសំណុំរឿង ០០៣៖ ខ្សែរ៉ូតកាបូបលុយរបស់សហរដ្ឋអាមេរិកប្រើប្រាស់ជាខ្សែតីវិញ* សារព័ត៌មានខេមបូឌា ដេលី ថ្ងៃទី ៦ ខែ កក្កដា ឆ្នាំ ២០១៦ គេហទំព័រ https://www.cambodiadaily.com/opinion/inducing-case-003-outcome-us-purse-strings-wielded-as-a-whip-115088/។

៤៧. ជាធម្មតាទេដែលការស្នើច្បាប់ថវិកានេះទទួលបានការចាប់អារម្មណ៍ពីប្រព័ន្ធផ្សព្វផ្សាយ និងមតិយោបល់ផ្សេងៗពីមជ្ឈដ្ឋានផ្សេងៗនៅក្នុងប្រទេសកម្ពុជានៅពេលនោះ[65]។ ការស្នើច្បាប់នេះត្រូវបានអនុម័តនៅក្នុងទម្រង់ដូចខាងក្រោមនៅថ្ងៃទី ៥ ខែ ឧសភា ឆ្នាំ ២០១៧៖

> "(២) សាលាក្តីខ្មែរក្រហម៖ ក្នុងចំណោមថវិកាត្រូវចំណាយតាមច្បាប់នេះដែលអាចផ្តល់ឱ្យដើម្បីជួយប្រទេសកម្ពុជា ក្រោមចំណងជើង "ថវិកាគាំទ្រសេដ្ឋកិច្ច" ថវិកាមិនលើសពី ១ ៥០០ ០០០ ដុល្លារ អាចផ្តល់ឱ្យបានជាការចូលរួមចំណែកថវិកាដល់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក)៖ ដរាបណា **ថវិកាបែបនេះអាចផ្តល់ជូនបានតែករណីដែលរដ្ឋមន្ត្រីការបរទេស បញ្ជាក់ និងរាយការណ៍ជូនគណៈកម្មាធិការទទួលបន្ទុកលើការផ្តល់ថវិកាថា ការចូលរួមចំណែកថវិកាបែបនេះគឺដើម្បីផលប្រយោជន៍របស់សហរដ្ឋអាមេរិក ហើយនឹងគាំទ្រការផ្តន្ទាទោស និងការដាក់ទោសបុគ្គលដែលទទួលខុសត្រូវចំពោះអំពើប្រល័យពូជសាសន៍នៅក្នុងប្រទេសកម្ពុជា នៅក្នុងរបៀបមួយដែលគួរឱ្យជឿទុកចិត្តបាន**។ ប្រសិនបើរដ្ឋមន្ត្រីការបរទេសមិនអាចធ្វើការបញ្ជាក់តាមលក្ខខណ្ឌជាមុននេះទេ ថវិកាបែបនេះត្រូវផ្តល់ឱ្យកម្មវិធីស្រាវជ្រាវ និងការអប់រំពាក់ព័ន្ធនឹង**អំពើប្រល័យពូជសាសន៍របស់ខ្មែរក្រហម**នៅក្នុងប្រទេសកម្ពុជា បន្ថែមពីលើថវិកាដែលអាចផ្តល់ឱ្យបាននៅកថាខណ្ឌ (៣)។ ដរាបណាថវិកាបែបនេះត្រូវមានការពិគ្រោះយោបល់ជាមុនជាមួយគណៈកម្មាធិការបែបនេះ ហើយត្រូវអនុវត្តតាមនីតិវិធីជូនដំណឹងជាទៀងទាត់របស់គណៈកម្មាធិការបែបនេះ។ ដរាបណា រដ្ឋមន្ត្រីការបរទេស ត្រូវស្វែងរកការបង់ថវិកាឱ្យវិញពីក្រុមប្រទេសផ្តល់ជំនួយសំខាន់ៗ ឱ្យទៅមជ្ឈ

[65] ថ្ងៃទី ៦ ខែ កក្កដា ឆ្នាំ ២០១៦ សារព័ត៌មាន ខេមបូឌា ដេលី បានចុះផ្សាយមតិយោបល់របស់សហមេធាវីអន្តរជាតិការពារក្តី មាស មុត ចំណងជើង *ជំរុញឱ្យមានលទ្ធផលសំណុំរឿង ០០៣៖ ខ្សែរ៉ូតកាបូបលុយរបស់សហរដ្ឋអាមេរិកប្រើប្រាស់ជាខ្សែតីវិញ* *Inducing Case 003 Outcome: US Purse Strings Wielded as a Whip* (https://www.cambodiadaily.com/opinion/inducing-case-003-outcome-us-purse-strings-wielded-as-a-whip-115088/)។ ចំពោះមតិយោបល់នេះ Heather Ryan អ្នកប្រឹក្សាម្នាក់នៅអង្គការ the Open Society Justice Initiative បានឆ្លើយនៅក្នុងអត្ថបទចំណង *សាលាក្តីបានប្រឡាក់ប្រឡូកដោយការជ្រៀតជ្រែកនយោបាយ ប៉ុន្តែមិនមែនមកពីសហរដ្ឋអាមេរិក ទេ* ថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ ២០១៦ *Tribunal Is Tainted by Political Interference, but Not From US* (https://www.cambodiadaily.com/opinion/tribunal-is-tainted-by-political-interference-but-not-from-us-115355/)។ ការជំទាស់វិញរបស់សហមេធាវីអន្តរជាតិ ឃើញមាននៅក្នុងអត្ថបទចំណងជើង *ការវិភាគរបស់អ្នកប្រឹក្សាអំពីការស្នើច្បាប់របស់ព្រឹទ្ធសភាសហរដ្ឋអាមេរិក ជ្រើសរើសតែអង្គហេតុល្អទេ* (*Consultant's Analysis of US Senate Bill Cherry-Picks Facts*) ថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០១៦ (https://www.cambodiadaily.com/opinion/consultants-analysis-of-us-senate-bill-cherry-picks-facts-115388/)។

មណ្ឌលឯកសារកម្ពុជា ចំពោះចំណាយដែលបានកើតឡើងដើម្បីគាំទ្រ អ.វ.ត.ក [គូសបញ្ជាក់បន្ថែម][66]។

៤៨. មិនចាំបាច់ឱ្យមានការគិតច្រើនទេ គឺដឹងហើយអំពីគោលជំហរដែលខ្លឹមសារនៃការស្នើច្បាប់នេះបានដាក់ឱ្យយើងស្ថិតនៅនោះ៖ ប្រសិនបើយើងចោទប្រកាន់មាស មុត បញ្ជូនទៅជំនុំជម្រះ អ្នកសង្កេតការណ៍តុលាការអាចនិយាយថា យើងចុះញ៉មធ្វើតាមការទាមទាររបស់សហរដ្ឋអាមេរិក ហើយប្រសិនបើយើងលើកលែងការចោទប្រកាន់ ឬមិនចោទប្រកាន់បញ្ជូនទៅជំនុំជម្រះវិញ យើងមានហានិភ័យអាចបាត់បង់ម្ចាស់ជំនួយដ៏សំខាន់មួយសម្រាប់ អ.វ.ត.ក។ សំណៅនៃច្បាប់ដែលបានអនុម័ត មិនមានលក្ខខណ្ឌសុទ្ធសាធដូចការស្នើច្បាប់ទេ ប៉ុន្តែ យ៉ាងណាក៏នៅតែបានជួយតិចតួចទេក្នុងការបន្ធូរសេចក្ដីព្រួយបារម្ភរបស់យើង៖ ច្បាប់នេះបញ្ជាក់ថា "ការផ្ដន្ទាទោស និងការដាក់ទោសបុគ្គលដែលទទួលខុសត្រូវចំពោះអំពើប្រល័យពូជសាសន៍នៅក្នុងប្រទេសកម្ពុជា នៅក្នុងរបៀបមួយដែលគួរឱ្យជឿទុកចិត្តបាន" គឺជាបុរេលក្ខខណ្ឌមួយ សម្រាប់បញ្ចេញថវិកា ហើយច្បាប់នេះចងភ្ជាប់ជំនួយនេះទៅនឹងបញ្ហាចោទថាតើការធ្វើដូច្នេះគឺ "ដើម្បីផលប្រយោជន៍ជាតិរបស់សហរដ្ឋអាមេរិក" ដែរឬអត់។ នេះម្យ៉ាងអាចបកស្រាយថាជាការតម្រូវឱ្យមានការចោទប្រកាន់បញ្ជូនទៅជំនុំជម្រះ និងផ្ដន្ទាទោសចំពោះអំពើប្រល័យពូជសាសន៍ និងជាការកំណត់ជាមុនអំពីបញ្ហាចោទអង្គច្បាប់ថាតើមានអំពើប្រល័យពូជសាសន៍នៅក្នុងប្រទេសកម្ពុជាដែរឬអត់ ជាបញ្ហាចោទមួយ ដែលត្រូវតែសម្រេចដោយតុលាការមានសមត្ថកិច្ចតែមួយគត់។ ម្យ៉ាងទៀត យើងឆ្ងល់ថាតើនៅពេលណាដែលការទប់ស្កាត់ ឬការដាក់ទោសចំពោះអំពើប្រល័យពូជសាសន៍អាចមិនមែនជា "ផលប្រយោជន៍ជាតិ"របស់ប្រទេសណាមួយ ជាពិសេសក្នុងករណីដែលប្រទេសនោះបានធ្វើសច្ចាប័នលើអនុសញ្ញាប្រឆាំងអំពើប្រល័យពូជសាសន៍ឆ្នាំ ១៩៤៨ រួចទៅហើយ។ ចុងក្រោយ ច្បាប់នេះទុកឱ្យសមាជិកម្នាក់នៃអង្គនីតិប្រតិបត្តិរបស់សហរដ្ឋអាមេរិក ជាអ្នកបញ្ជាក់អំពីភាពអាចទុកចិត្តបាននៃកិច្ចដំណើរការនីតិវិធីនៅចំពោះមុខ អ.វ.ត.ក ដើម្បីបញ្ចេញថវិកានោះ។ តាមការយល់ឃើញរបស់យើង អ្នកសង្កេតការណ៍ជាទូទៅអាចត្រូវអត់ឱនឱ្យបានប្រសិនគាត់គិតថា នេះ

[66] ផ្នែក 7043(c)(2) ច្បាប់ផ្ដល់ថវិកាសរុប ឆ្នាំ ២០១៧ គេហទំព័រ https://www.congress.gov/bill/115th-congress/house-bill/244/។

យ៉ាងហោចណាស់ក៏ជាករណីបឋមថាមានឥទ្ធិពលដោយប្រយោលមកលើលទ្ធផលជាក់ស្តែងនៃសំណុំរឿងណាមួយដែរ[67]។

៤៩. ប៉ុន្តែ ឥទ្ធិពលផ្ទាល់ទាក់ទងនឹងលទ្ធផលគឺជាទិដ្ឋភាពមួយតែប៉ុណ្ណោះ។ ការបង្ហាញការមិនពេញចិត្តជាមួយនឹងល្បឿននៃការស៊ើបសួរគឺជាទិដ្ឋភាពមួយផ្សេងទៀត ហើយនេះជាប់ពាក់ព័ន្ធទៅនឹងបញ្ហាមុន គឺការកំណត់ថវិកាផ្អែកតាមលទ្ធផល។ យើងមានសំណើជាដដែលៗពីសមាជិកនៃក្រុមប្រទេសផ្តល់ជំនួយសំខាន់ៗ នៅក្នុងអំឡុងពេលរៀបចំថវិកានៅឆ្នាំ ២០១៦ ជាសំណើដែលបានធ្វើឡើងក្នុងកម្រិតមួយលម្អិត ដែលយើងយល់ឃើញថាមានបញ្ហានៅក្នុងបរិយាកាសតុលាការ។

៥០. [redacted]

៥១. ឥឡូវនេះ អស់ពេលមួយរយៈហើយ យើងបានពន្យល់អំពីមូលហេតុដែលនាំឱ្យមានការយឺតយ៉ាវជាដដែលៗ ដោយធ្វើការពន្យល់តាមរយៈការចូលរួមចំណែករបាយការណ៍របស់យើងនៅក្នុងរបាយការណ៍បញ្ចប់ការងារប្រចាំត្រីមាសដែលរៀបចំឡើងដើម្បីឱ្យ អ.ស.ប រាជរដ្ឋាភិបាលកម្ពុជា ក្រុមប្រទេសផ្តល់ជំនួយសំខាន់ៗ និងសាធារណជន ទទួលបានព័ត៌មានបច្ចុប្បន្នភាព។ ដោយពិនិត្យថាមានការពន្យល់ដូច្នេះហើយ សំណើខាងលើនេះអាចបកស្រាយថាមានបំណងចង់បានព័ត៌មានកាន់តែច្បាស់លាស់ជាងនេះទៀតអំពីយុទ្ធសាស្ត្រស៊ើបសួររបស់យើង

---

[67] *Colorandi causa* វិធីស្រដៀងគ្នានេះត្រូវបានអនុវត្តដោយសហរដ្ឋអាមេរិកជាថ្មីម្តងទៀតនៅក្នុងបរិបទនៃសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខ អ.ស.ប លេខ ១៤២២-សូមមើល Aly Mokhtar *សិល្បៈនៃការបន្លំ៖ សហរដ្ឋអាមេរិក សេចក្តីសម្រេចលេខ ១៤២២ និងអំណាចពន្យារពេលរបស់ក្រុមប្រឹក្សាសន្តិសុខ នៅក្នុងលក្ខន្តិកៈទីក្រុងរ៉ូម* International Criminal Law Review (3) ឆ្នាំ ២០០៣ ទំព័រ ២៩៥-៣៤៤។

ការគ្រប់គ្រងសំណុំរឿង និងទង្វើរបស់ភាគីសំណុំរឿង ដែលការធ្វើរបៀបនេះតាមការយល់ឃើញរបស់យើង បានរំលោភលើគោលការណ៍រក្សាការសម្ងាត់នៃការស៊ើបសួរ។

៥២. [redacted]

៥៣. [redacted]

៥៤. [redacted]

៥៥. ក្រៅពីបង្ហាញពីកម្រិតនៃចេតនាចូលជ្រៀតជ្រែកក្នុងការគ្រប់គ្រងសំណុំរឿងតុលាការ និងការធ្វើសេចក្តីសម្រេចរបស់តុលាការនោះ នេះក៏បង្ហាញថា តាំងពីដំបូង នៅខែ តុលា ឆ្នាំ ២០១៦ អ.ស.ប និងក្រុមប្រទេសផ្តល់ជំនួយសំខាន់ៗ ទទួលបានការជូនដំណឹងយ៉ាងពេញលេញអំពីការដែលអាចផ្អាកកិច្ចដំណើរការនីតិវិធី ប្រសិនបើការផ្តល់ថវិកាមិនត្រូវតាមតម្រូវការ

ស្នូលរបស់ ក.ស.ច.ស ទេ។

៥៦. ចុងក្រោយបង្អស់ ប៉ុន្តែមិនមែនមិនសំខាន់ទេ ចំពោះការដាក់ឱ្យប្រើប្រាស់នូវវិធានថ្មីក្នុង ៦៦ *ស្ទូន* មានការផ្តូនដំណឹងជាសាធារណៈថា ស.ច.ស.អ បានប្រើប្រាស់វិធាននេះនៅក្នុងសំណុំរឿងទាំងអស់ក្រៅពីសំណុំរឿង ០០៤/១។ ការដាក់ឱ្យប្រើប្រាស់វិធាននេះគឺភាគច្រើនដោយសារថាមានសេចក្តីព្រួយបារម្ភពីប្រទេសម្ចាស់ជំនួយទាក់ទងនឹងរយៈពេលនៃកិច្ចដំណើរការនីតិវិធី និងគោលបំណងកាត់បន្ថយភាពស្មុគស្មាញនៃសំណុំរឿងដើម្បីទទួលបានស្ថានការណ៍មួយដែលចុងក្រោយបំផុត ការជំនុំជម្រះក្តីនៅតែអាចគ្រប់គ្រងបានហើយមានរយៈពេលខ្លី[68]។

## ង. យុទ្ធសាស្ត្រច្រកចេញ

៥៧. យើងកត់សម្គាល់ថា បច្ចុប្បន្ននេះ មិនមានការពិចារណាលើយុទ្ធសាស្ត្រច្រកចេញទេ។ យើងយោងលើការពន្យល់របស់យើងនៅក្នុងដីកាដំណោះស្រាយ (ផ្នែកសំអាងហេតុ) នៅក្នុងសំណុំរឿង ០០៤/១[69] អំពីកង្វះយុត្តាធិការនៅក្នុងតុលាការធម្មតារបស់ប្រទេសកម្ពុជា។ ហេតុនេះការមិនមានថវិកាគ្រប់គ្រាន់នាពេលអនាគត អាចមានន័យថាធ្វើឱ្យកិច្ចដំណើរការនីតិវិធីដែលមិនទាន់ចប់នេះបរាជ័យដោយគ្មានច្បាប់ទម្លាប់ និងជាប់គាំងដោយគ្មានច្បាប់ចែង។

## ច. សេចក្តីបញ្ជាក់របស់ការិយាល័យរដ្ឋបាលអំពីតំណែងទំនេរនៅ ក.ស.ច.ស

៥៨. សារណារបស់ការិយាល័យរដ្ឋបាល[70] ហាក់ដូចជាបង្កើតឱ្យមានការចាប់អារម្មណ៍ថា ស.ច.ស.អ មិនបានស្នើសុំតំណែងនានាឱ្យបានទាន់ពេលទេ ទោះបីជាថាមានថវិកាក៏ដោយ ហើយតំណែងទាំងនោះត្រូវឯកភាពឱ្យបានឆាប់រហ័ស នៅពេលដែលសំណើបញ្ជូនមក។ នេះគឺជា

---

[68] *សូមមើល* សេចក្តីប្រកាសព័ត៌មានចុះថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០១៥ ""សម័យប្រជុំពេញអង្គលើកទី ១១ បានបញ្ចប់" ដែលមានការប្រកាសថា ការធ្វើវិសោធនកម្មនេះត្រូវបានអនុម័តក្នុងគោលបំណងដើម្បីពន្លឿនកិច្ចដំណើរការនីតិវិធីនៅចំពោះមុខ អ.វ.ត.ក។

[69] សំណុំរឿង ០០៤/១ ឯកសារ D308/1 *ដីកាដំណោះស្រាយ (ផ្នែកសំអាងហេតុ)* ថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១៧ កថាខណ្ឌ ១១-២៥។

[70] សំណុំរឿង ០០៤/២ ឯកសារ D349/3 *មតិយោបល់របស់ការិយាល័យរដ្ឋបាល ស្តីពីស្ថានភាពថវិការបស់ អ.វ.ត.ក និងផលប៉ះពាល់មកលើសំណុំរឿង ០០៣ សំណុំរឿង ០០៤ និងសំណុំរឿង ០០៤/២* ថ្ងៃទី ៥ ខែ មិថុនា ឆ្នាំ ២០១៧ កថាខណ្ឌ ១២។

កត្តាតូចមួយ ប៉ុន្តែ វាបង្ហាញពីរូបភាពមិនត្រឹមត្រូវនៃការទាក់ទងគ្នារវាងការិយាល័យរដ្ឋបាលជាមួយ ក.ស.ច.ស ដែលបញ្ហានេះចាំបាច់ត្រូវដាក់ឱ្យយល់ឱ្យបានត្រឹមត្រូវដើម្បីឱ្យចប់ចុងចប់ ដើម។

៥៩. ទីមួយ បញ្ហានេះត្រូវពិនិត្យដោយប្រៀបធៀបជាមួយនឹងប្រវត្តិទូទៅនៃនីតិវិធីជ្រើសរើសបុគ្គលិកដ៏យូរស្មុគស្មាញរបស់ អ.ស.ប ដែលមិនត្រូវតាមស្ថាប័នមួយ ដូចជា តុលាការព្រហ្មទណ្ឌពិសេស ជាដើម ដែលបង្កើតឡើងដើម្បីអនុវត្តកិច្ចដំណើរការនីតិវិធីឱ្យបានលឿន ហើយមានអាយុកាលមានកំណត់តាមការរំពឹងទុក គឺខុសពីស្ថាប័នរដ្ឋបាលអចិន្ត្រៃយ៍ ឧទាហរណ៍ ដូចជា ទីស្នាក់ការ អ.ស.ប ជាដើម។ សំណើមួយនៅឆ្នាំ ២០១៦ ដែល ស.ច.ស.អ ផ្ញើទៅទីស្នាក់ការ អ.ស.ប តាមរយៈការិយាល័យរដ្ឋបាល សុំឱ្យ ក.ស.ច.ស រួចផុតពីលក្ខខណ្ឌជ្រើសរើសបុគ្គលិកទាំងនោះដើម្បីឱ្យមានបុគ្គលិកជំនួសឆាប់រហ័ស ត្រូវទីស្នាក់ការ អ.ស.ប ធ្វើការបដិសេធភ្លាមៗ ដោយ ស.ច.ស.អ ទទួលដំណឹងពីការិយាល័យរដ្ឋបាល។ ត្រូវតែសង្កត់ធ្ងន់ថា ដោយសារភាពមិនច្បាស់លាស់អំពីស្ថានភាពថវិការបស់តុលាការ និងដោយសារពាក់ព័ន្ធនឹងរយៈពេលនៃកិច្ចសន្យាការងារ ទើបនៅឆ្នាំកន្លងមកនេះ មន្ត្រីច្បាប់ និងអ្នកស៊ើបអង្កេតមួយចំនួន បានចាកចេញពី ក.ស.ច.ស ដើម្បីទទួលយកការងារមានស្ថេរភាពជាងនេះ[71]។ ហេតុនេះ កន្លងមក ចាំបាច់ត្រូវអនុវត្តនីតិវិធីមួយចំនួនដែលត្រូវចំណាយពេលក្នុងការជ្រើសរើសបុគ្គលិក ហើយអាចត្រូវអនុវត្តដូច្នេះទៀតនៅពេលអនាគត។ តាមប្រព័ន្ធបច្ចុប្បន្ននេះ អាចស៊ីពេលប្រហែលជា ២ ខែ ចាប់ពីពេលប្រកាសតំណែងទំនេររហូតដល់ការជ្រើសរើសសមាជិកបុគ្គលិកថ្មីម្នាក់របស់ អ.ស.ប[72] តែ ចំណាយពេលតិចជាង

---

[71] ករណីនេះកើតឡើងជាពិសេសនៅក្នុងសំណុំរឿង ០០៣ ដែល ស.ច.ស.អ ទើបតែដឹងពេលថ្មីៗនេះថា នៅឆ្នាំ ២០១៧ ការិយាល័យរបស់គាត់នឹងបាត់បង់សមាជិកក្រុមការងារច្បាប់ជាន់ខ្ពស់ម្នាក់ដែលបានធ្វើការយូរហើយ តាមរយៈការលាលែងពីតំណែង បន្ថែមពីលើមន្ត្រីច្បាប់ម្នាក់ទៀតដែលចាកចេញក្នុងពេលដំណាលគ្នានេះដោយសារគាត់ត្រូវទៅបន្តសិក្សាថ្នាក់ក្រោយបរិញ្ញាបត្រ។

[72] រយៈពេលនេះពិតជាមិនរាប់បញ្ចូលរយៈពេល ២១ ថ្ងៃដែលត្រូវចំណាយនៅចន្លោះពេលរវាងការជ្រើសរើស និងការរៀបចំការធ្វើដំណើរសម្រាប់មនុស្សដែលបានជ្រើសរើស ប្រសិនបើមិនអនុញ្ញាតឱ្យមានករណីលើកលែង។ គួរកត់សម្គាល់ថា ស.ច.ស.អ និងប្រធានការិយាល័យរបស់គាត់ បានចំណាយថ្លៃធ្វើដំណើរតាមយន្តហោះរបស់អ្នកប្រឹក្សាម្នាក់ ដោយប្រើថវិកាពីហោប៉ៅផ្ទាល់ខ្លួន ដោយសារថាមិនមានការលើកលែងរយៈពេល ២១ ថ្ងៃនេះ ហើយប្រសិនបើត្រូវចំណាយពេល ២១ នេះថ្ងៃវិញ នោះ គឺត្រូវខាតបង់វឌ្ឍនភាពការងារដែលមិនអាចទទួលយកបានទេនៅក្នុងសំណុំរឿងដែលគាត់ត្រូវបានជ្រើសរើសឱ្យធ្វើការ។

នេះទេប្រសិនបើស្នើសុំតំណែងជាអ្នកប្រឹក្សាវិញ។ ប៉ុន្តែ យើងបានទទួលដំណឹងពីការិយាល័យរដ្ឋបាល ថា ទីស្នាក់ការ អ.ស.ប កាន់តែមិនពេញចិត្តជាមួយនឹងការប្រើប្រាស់កិច្ចសន្យាការងារប្រភេទជាអ្នកប្រឹក្សា។ ហេតុនេះ ការបដិសេធភ្លាមៗមិនអនុញ្ញាតតាមសំណើសុំឱ្យមានដំណើរការជ្រើសរើសបុគ្គលិកឱ្យបានលឿនជាងនេះនោះ គឺមិនគួរណាត្រូវធ្វើការបដិសេធដូច្នេះទេ ពីព្រោះថា ប្រសិនបើមិនបានបដិសេធវិញ អាចទប់ស្កាត់មិនឱ្យមានការពន្យារពេលរាប់ខែ ហើយអាចចំណេញថវិកាបានច្រើនទៀតផង។

៦០. [redacted]

## ខ. សេចក្តីសន្និដ្ឋាន

៦១. ចម្លើយតបរបស់ អ.ស.ប និងក្រុមប្រទេសផ្តល់ជំនួយសំខាន់ៗដែលបានដាក់តាមរយៈការិយាល័យរដ្ឋបាល មិនដល់កម្រិតច្បាស់លាស់ទាំងស្រុងដែលយើងបានសង្ឃឹមឡើយ។ ប៉ុន្តែ ចម្លើយតបទាំងនេះ មិនដល់ថ្នាក់ដែលខ្វះការយកចិត្តទុកដាក់ទាំងស្រុងលើសេចក្តីព្រួយបារម្ភរបស់យើងទេ ជាពិសេសប្រសិនបើពិនិត្យមើលការវិវត្តនៃការផ្តល់ថវិកាចាប់តាំងពីពេលចេញសំណើរួចហើយ។

៦២. ជាពិសេស ក្រុមប្រទេសផ្តល់ជំនួយសំខាន់ៗបានផ្តល់ការធានាជាលាយលក្ខណ៍អក្សរថា "ប្តេជ្ញាចិត្តយ៉ាងមុតមាំ"ក្នុងការបន្តផ្តល់ថវិកាដល់ អ.វ.ត.ក ជាការប្តេជ្ញាមួយដែលមានភស្តុតាងបញ្ជាក់រហូតមកដល់ពេលនេះ តាមរយៈការបង្កើនថវិកាយ៉ាងលឿនសម្រាប់ឆ្នាំ ២០១៧ បើប្រៀបធៀបជាមួយនឹងការបញ្ជាក់ពីមុនៗដែលយើងទទួលបានពីការិយាល័យរដ្ឋបាល និងអ្នកជំនាញពិសេសរបស់អគ្គលេខាធិការ។ តាមដែលយើងដឹង នេះគឺជាលើកដំបូង

ហើយដែល អ.ស.ប និងជារួម ក្រុមប្រទេសផ្ដល់ជំនួយសំខាន់ៗ បានធ្វើការប្ដេជ្ញាចិត្តបែបនេះដោយផ្ទាល់តាមរយៈកិច្ចអន្តរាគមន៍នៅក្នុងកិច្ចដំណើរការនីតិវិធីរបស់តុលាការមួយ។ ដោយសារលក្ខណៈនៃថវិកាឧបត្ថម្ភធនណាមួយពី អ.ស.ប ទើប ជាក់ស្ដែង អ.ស.ប និងជារួម ក្រុមប្រទេសផ្ដល់ជំនួយសំខាន់ៗ គឺជាអ្នកទទួលខុសត្រូវចំពោះការផ្ដល់ថវិកាសម្រាប់ភាគីអន្តរជាតិ និងថវិកាខ្លះសម្រាប់ភាគីជាតិដែរ។ យើងជឿថា ក្រុមប្រទេសផ្ដល់ជំនួយសំខាន់ៗ ដឹងអំពីការទទួលខុសត្រូវសីលធម៌ខ្ពស់តាមលក្ខខណ្ឌនៃការប្ដេជ្ញាចិត្តជាលាយលក្ខណ៍អក្សរបែបនេះ ជាពិសេសតាមការយល់ឃើញរបស់សហគមន៍អន្តរជាតិ និងជារួម តាមការយល់ឃើញរបស់ប្រជាជនកម្ពុជា ជាពិសេសដោយពិនិត្យមើលគោលជំហររបស់ក្រុមប្រទេសផ្ដល់ជំនួយសំខាន់ៗលើយុទ្ធសាស្ត្រច្រកចេញ និងផលលំបាកដោយសារមិនមានយុទ្ធសាស្ត្រច្រកចេញនេះក្នុងករណីបរាជ័យផ្នែកថវិកាដែលយើងបានបង្ហាញខាងលើ។

៦៣. យើងយល់ឃើញថា សម្រាប់ពេលឥឡូវនេះ មានវិធីមិនសូវច្បាស់ដើម្បីដោះស្រាយបញ្ហានេះ៖ កម្រិតនៃការប្ដេជ្ញាចិត្តជាថ្មីរបស់ក្រុមប្រទេសផ្ដល់ជំនួយសំខាន់ៗ នឹងត្រូវតាមដានយ៉ាងងាយតាមរយៈចំនួនថវិកាដែលត្រូវផ្ដល់បន្ថែមមកទៀតពីលើចំនួនដែលបានផ្ដល់ជាក់ស្ដែងរួចហើយសម្រាប់ពេលវេលាសេសសល់នៃឆ្នាំ ២០១៧ និងលក្ខណៈនៃការចរចាថវិកាខាងមុខនេះសម្រាប់ឆ្នាំ ២០១៨ ដោយក្រុមប្រទេសផ្ដល់ជំនួយសំខាន់ៗត្រូវគោរពតាមការសន្យាផ្ដល់ថវិកាដែលខ្លួនបានអនុម័តទាំងស្រុង ហើយមិនត្រូវធ្វើការប្រកាសតាមក្រោយមកវិញថា ទោះបីជាមានកង្វះថវិកាក៏ដោយ ក៏តុលាការនៅតែអាចដំណើរការបានគួរជាទីពេញចិត្ត។ សេចក្ដីសម្រេចថាតើអ្វីដែលគួរជាទីពេញពេញចិត្តខាងការជំនុំជម្រះក្ដីដោយយុត្តិធម៌នោះ គឺចុងក្រោយជាសេចក្ដីសម្រេចសម្រាប់ចៅក្រម ហើយមិនមែនជាសេចក្ដីសម្រេចសម្រាប់អ្នកផ្សេងណាម្នាក់ឡើយ។ នៅក្នុងបរិបទនេះ យើងសូមកោតសរសើរដែលកិច្ចសន្យាការងារបុគ្គលិកត្រូវបានបន្តរួចហើយនៅខែ មិថុនា ឆ្នាំ ២០១៧ រហូតដល់ចុងឆ្នាំនេះ ដែលនេះយ៉ាងហោចណាស់ក៏ផ្ដល់ជាការព្យាករបានខ្លះអំពីការងារបុគ្គលិក និងផែនការស៊ើបសួរនៅក្នុងពេលដំណាលគ្នានេះដែរ។ យើងចាត់ទុកថា នេះគឺជាសញ្ញាដំបូងដែលបង្ហាញថា មានការយល់ដឹងហើយអំពីសេចក្ដីព្រួយបារម្ភរបស់យើង។ ត្រង់នេះ នាពេលថ្មីៗនេះ តាមរយៈសារព័ត៌មានភ្នំពេញប៉ុស្ដិ៍ យើងបានដឹងថា សហភាពអឺរ៉ុប បានបង្ហាញឱ្យឃើញថាបានសន្យាផ្ដល់ថវិកាចំនួន ១០ លានអឺរ៉ូដល់ អ.វ.ត.ក សម្រាប់ទូទាត់ចំណាយរបស់តុលាការរហូតដល់ឆ្នាំ២០១៩។

នាពេលថ្មីៗនេះ យើងក៏ទទួលបានដំណឹងថា រដ្ឋាភិបាលជប៉ុន បានប្រកាសផ្តល់ជំនួយថ្មីចំនួនជាង ១.២ លានដុល្លារដល់ភាគីអន្តរជាតិនៅ អ.វ.ត.ក សម្រាប់ឆ្នាំសារពើពន្ធ ២០១៧[73]។ យើងសូមស្វាគមន៍ការសន្យា និងជំនួយទាំងនេះ ថាជាភស្តុតាងបន្ថែមទៀតគាំទ្រការប្តេជ្ញាចិត្តយ៉ាងមុតមាំ ដែលក្រុមប្រទេសផ្តល់ជំនួយសំខាន់ៗបានបញ្ជាក់ដើម្បីបញ្ចប់កិច្ចដំណើរការនីតិវិធីដែលមិនទាន់ចប់នៅចំពោះមុខ អ.វ.ត.ក[74]។ ប៉ុន្តែ យើងកត់សម្គាល់ថា ជាពិសេសដោយគិតពីការដែលអាចមានផលប៉ះពាល់វខានបណ្តាលមកពីកិច្ចដំណើរការនីតិវិធីបច្ចុប្បន្ននេះទាក់ទងនឹងសំណើ នោះ គឺមិនគួរ ហើយក៏មិនមានប្រសិទ្ធផលដែរដែលយើងបែរជាត្រូវដឹងដំណឹងអំពីការសន្យារបស់សហភាពអឺរ៉ុបតាមរយៈប្រព័ន្ធផ្សព្វផ្សាយទៅវិញ មិនមែនតាមរយៈការិយាល័យរដ្ឋបាល (ឬប្រទេសផ្តល់ជំនួយសំខាន់ៗ) ឧទាហរណ៍ដូចអាចធ្វើបានតាមរយៈអនុស្សរណៈរបស់ការិយាល័យរដ្ឋបាលចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១៧[75] ជាដើម។ ហេតុនេះ ការបង្កើនតម្លាភាព និងការជូនដំណឹងភ្លាមៗអំពីការវិវត្តថវិកា-ជាបញ្ហាមួយដែលយើងបានផ្តល់តម្រុយថាមានសារៈសំខាន់ណាស់សម្រាប់សំណុំរឿងទាំងអស់នោះ គួរតែជាបញ្ហាសំខាន់ណាស់ចំពោះការិយាល័យរដ្ឋបាល នាពេលខាងមុខទៀត។

៦៤. ទទ្បីករណីដែលបានលើកឡើងដោយ អ.ស.ប និងក្រុមប្រទេសផ្តល់ជំនួយសំខាន់ៗ ចុងក្រោយបំផុតហ្នឹងគឺជាសញ្ញា និងមានលក្ខណៈជាប្រព័ន្ធជាទូទៅជាង គឺថា ទោះបីជាមានសាលាក្តីព្រហ្មទណ្ឌអន្តរជាតិសម័យទំនើបចាប់តាំងពីដើមទស្សវត្សរ៍ឆ្នាំ ១៩៩០ និងពាក្យបណ្តឹងកើតឡើងដដែលៗនៅទូទាំងតុលាការទាំងនោះអំពីកង្វះថវិកា ក៏ដោយ ក៏សហគមន៍រដ្ឋនានាមិនទាន់បានបង្កើតគំរូថវិកាណាមួយគួរឱ្យទុកចិត្តបាន ដែលអាចឱ្យតុលាការដំណើរការទៅនៅថ្នាក់អន្តរជាតិ ឱ្យដូចដែលតុលាការ ដំណើរការទៅនៅថ្នាក់ជាតិតាមប្រព័ន្ធថវិកាផ្អែកលើចំណូលពន្ធ ហើយក៏អាចឱ្យតុលាការ បំពេញតាមតម្រូវការឯករាជ្យភាពតុលាការ នៅក្នុង

---

[73] អ.វ.ត.ក សេចក្តីប្រកាសព័ត៌មាន *ជប៉ុន ផ្តល់វិភាគទានថ្មីជូនអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា* ថ្ងៃទី ៣ ខែ សីហា ឆ្នាំ ២០១៧ អាចរកបានតាមរយៈ៖ https://www.eccc.gov.kh/sites/default/files/media/Press%20Release%20Japan%20makes%20a%20new%20contribution%20to%20the%20ECCC%20English.pdf.។

[74] សូមមើលអត្ថបទរបស់ភ្នំពេញប៉ុស្តិ៍ ចំណងជើង *សាលាក្តីខ្មែរក្រហមទទួលថវិកា ពន្យារពេលកាលបរិច្ឆេទកំណត់បញ្ចប់រឿងក្តី* ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១៧ អាចរកបានតាមរយៈ៖ http://www.phnompenhpost.com/national/khmer-rouge-tribunal-gets-funds-case-deadline-extension។

[75] [redacted]

បរិយាកាសនយោបាយ និងស្ថាប័នដែលមានការជំរុញលើសលុបពីអង្គនីតិប្រតិបត្តិ។ ក្រុមប្រទេសផ្តល់ជំនួយសំខាន់ៗ ខ្លួនឯង បានទទួលស្គាល់ថា គំរូថវិកាស្ម័គ្រចិត្តមិនមែនជាគំរូល្អបំផុតទេ។ ការជ្រើសរើសគំរូ និងជាថ្មីម្តង ការទទួលស្គាល់ខ្លួនឯងរបស់ អ.ស.ប និងក្រុមប្រទេសផ្តល់ជំនួយសំខាន់ៗ គឺជាបញ្ហាមួយ ប៉ុន្តែ ការអនុវត្តជាក់ស្តែងរបស់ប្រទេសផ្តល់ជំនួយតាមកាតព្វកិច្ចរបស់ខ្លួនត្រូវផ្តល់ថវិកា គឺជាបញ្ហាមួយផ្សេងទៀត។

៦៥. ហេតុនេះ នៅពេលដែលធ្វើការពិចារណាយ៉ាងច្រើន និងទោះបីជានៅមានមន្ទិលក៏ដោយ ក៏យើងគិតឲ្យមានតុល្យភាពដែរ គឺថា មិនទាន់ដល់កន្លែង និងពេលវេលា ដែលត្រូវដោះស្រាយចំណុចខ្វះខាតជាប្រព័ន្ធខាងលើនេះ ដោយចេញដីកាសម្រេចផ្អាកកិច្ចដំណើរការនីតិវិធីទាំងស្រុងទេ។

៦៦. យ៉ាងណាក៏ដោយ វិធីសាស្ត្រអត់ធ្មត់តាមផ្លូវតុលាការនេះនៅតែអាចអនុវត្តបាន តែក្នុងករណីដែលការផ្តល់ថវិកានាពេលអនាគតបំពេញតាមលក្ខខណ្ឌតម្រូវរបស់តុលាការ ដូចបានបង្ហាញនៅក្នុងសំណើថវិកានាពេលខាងមុខនេះរបស់តុលាការ ដោយត្រូវគោរពតាមថវិកាដែលបានទទួលយក និងអនុម័តដោយ អ.ស.ប និងក្រុមប្រទេសផ្តល់ជំនួយសំខាន់ៗ ឲ្យបានទាន់ពេលវេលា ហើយគួរមានការបញ្ជាក់ឲ្យបានលឿន និងគួរឲ្យទុកចិត្តបានអំពីការគោរពតាមថវិកានេះ ព្រមទាំងមានមធ្យោបាយជូនដំណឹងរួម។ គ្មានមធ្យោបាយណាដែលអាចមានពាក្យថា "គឺ" និង"គួរ"កំណត់ដែនដំណាត់បទដ្ឋាននៃឯករាជ្យភាពតុលាការ ការជំនុំជម្រះក្តីដោយយុត្តិធម៌ និងដំណើរការនីតិវិធីត្រឹមត្រូវ ដែលពាក្យទាំងពីរនេះមាននៅក្នុងការអនុវត្តមិនល្អជាទូទៅនៃការផ្តល់ថវិកានៅថ្នាក់អន្តរជាតិ។

៦៧. ហេតុនេះ យើងនៅតែពិនិត្យបញ្ហានេះយ៉ាងសកម្ម ហើយនឹងចាត់វិធានការចាំបាច់ ប្រសិនបើបញ្ហាធ្លាក់ដុនដាបម្តងទៀតដល់កម្រិតមួយដែលតាមការយល់ឃើញរបស់យើង ឯករាជ្យភាពតុលាការ ភាពយុត្តិធម៌ និងសុចរិតភាពនៃកិច្ចដំណើរការនីតិវិធី ត្រូវបានគំរាមកំហែង។

៦៨. យើងនឹងអញ្ជើញការិយាល័យរដ្ឋបាល ឲ្យធ្វើបច្ចុប្បន្នភាពជាលាយលក្ខណ៍អក្សរជាទៀងទាត់អំពីស្ថានភាពថវិកា អាចតាមរយៈការបន្ថែមផ្នែកថ្មីមួយនៅក្នុងរបាយការណ៍បញ្ចប់ការងារប្រចាំត្រីមាស តាមពិតទៅ គឺដើម្បីជាកញ្ចក់ឆ្លុះបញ្ចាំងនៃវិធីសាស្ត្រកំណត់ថវិកាផ្អែកតាមលទ្ធផលដែលបានប្រើប្រាស់សម្រាប់ប្រៀបធៀបការងារតុលាការ។ ការធ្វើរបៀបនេះក៏ផ្តល់

ការទទួលខុសត្រូវជាសាធារណៈចំពោះការវិវត្តនៃការផ្តល់ថវិកា ពោលគឺនៅក្រៅការស៊ើបសួរដែលត្រូវរក្សាការសម្ងាត់។

**អាស្រ័យហេតុនេះ យើង**[76]**៖**

៦៩. **ជូនដំណឹង** ភាគី និងការិយាល័យរដ្ឋបាល ថា សម្រាប់ពេលឥឡូវនេះ យើងពន្យារពេលចេញដីកាសម្រេចលើការផ្អាកកិច្ចដំណើរការនីតិវិធី ប៉ុន្តែ យើងនៅតែពិនិត្យបញ្ហានេះយ៉ាងសកម្ម រហូតដល់ពេលចេញដីកាដំណោះស្រាយចុងក្រោយ។ ប្រសិនបើកង្វះថវិកានាពេលអនាគត ឬ ភាពមិនប្រាកដប្រជាផ្នែកហិរញ្ញវត្ថុ គំរាមកំហែងដល់ឯករាជ្យភាពតុលាការ ភាពយុត្តិធម៌ និង សុចរិតភាពនៃកិច្ចដំណើរការនីតិវិធីនោះ យើងនឹងចាត់វិធានការដែលយើងយល់ឃើញថា ចាំបាច់ដើម្បីដោះស្រាយស្ថានភាពនេះ។

៧០. **អញ្ជើញ** ការិយាល័យរដ្ឋបាល ធ្វើសេចក្តីរាយការណ៍នាពេលអនាគត យ៉ាងហោចណាស់ប្រចាំត្រីមាសអំពីការផ្តល់ថវិកា ដោយប្រៀបធៀបជាមួយនឹងថវិកាដែលបានឯកភាព ឧទាហរណ៍ ដោយបន្ថែមផ្នែកថ្មីមួយស្តីពីការវិវត្តនៃការផ្តល់ថវិកានៅក្នុងរបាយការណ៍បញ្ចប់ការងារប្រចាំត្រីមាសដែលផ្សព្វផ្សាយជាសាធារណៈ។

៧១. **ជូនដំណឹង** ភាគី និងការិយាល័យរដ្ឋបាល ថា ដីកាសម្រេចនេះគឺជាការសម្ងាត់ ហើយយើងចាត់ទុកថា ការដាក់បង្ហាញដីកាសម្រេចនេះ ឬផ្នែកណាមួយនៃអត្ថបទ ឬខ្លឹមសារនៃដីកាសម្រេចនេះដែលមិនមាននៅក្នុងសំណៅសាធារណៈដោយមានការកោសលុប គឺជាការរំលោភលើវិធានផ្ទៃក្នុង ៣៥(១)(ក) ហើយយើងនឹងចាត់នីតិវិធីលើបទល្មើសណាមួយនាពេលអនាគត យោងតាមវិធានផ្ទៃក្នុង ៣៥(២) និង (៤) ដោយភ្ជាប់ជាមួយនឹងមាត្រា ៣១៤ នៃក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ២០០៩។

---

[76] ចៅក្រមទាំងពីរ ចុះហត្ថលេខាលើដីកាសម្រេចនេះរួមគ្នា ប៉ុន្តែ ស.ច.ស. ជាតិ សូមរំឭកថា គាត់មិនទទួលស្គាល់ ឬក៏ទទួលយកថាមានសុពលភាពទេចំពោះឯកសារណាដែលបានបង្កើត និង/ឬដាក់ដោយអតីតស.ច.ស. បម្រុងអន្តរជាតិ Kasper-Ansermet ហេតុនេះ ការដាក់លេខឯកសារសំណុំរឿងគួរដាក់លេខបន្តពីឯកសារចុងក្រោយដែលបានដាក់មុនពេល ស.ច.ស.អ Siegfried Blunk បានលាលែងតំណែង ដោយមិនរាប់បញ្ចូលដីកា និងដីកាសម្រេចនានាដែលចេញដោយ ចៅក្រម Kasper-Ansermet ឡើយ។

៧២. **អនុញ្ញាតឲ្យ** ការិយាល័យរដ្ឋបាល បញ្ជូនដីកាសម្រេចនេះបន្តទៅអាជ្ញាធរពាក់ព័ន្ធនានានៅក្នុងរាជរដ្ឋាភិបាលកម្ពុជា អ.ស.ប និងប្រទេសផ្តល់ជំនួយសំខាន់ៗ។

៧៣. **បង្គាប់** ក្រឡាបញ្ជី ត្រូវដាក់សំណៅមួយច្បាប់នៃដីកាសម្រេចនេះចូលក្នុងសំណុំរឿង ០០៣ និងសំណុំរឿង ០០៤ ហើយដាក់សំណៅសាធារណៈដោយមានការកោសលុបចូលក្នុងសំណុំរឿង ០០៣ សំណុំរឿង ០០៤ និងសំណុំរឿង ០០៤/២។

ភ្នំពេញ ថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០១៧

**សហចៅក្រមស៊ើបអង្កេត**
Co-Investigating Judges
Co-juge d'instruction

**ចៅក្រម យូ ប៊ុនឡេង** **ចៅក្រម Michael BOHLANDER**